ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់ស្តីពី

# ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

# និង

# ច្បាប់ស្តីពី

# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

# និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

# ច្បាប់
# ស្តីពី
# ការគ្រប់គ្រងរដ្ឋបាល
# ឃុំ សង្កាត់

# មាតិកា

## ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់


ជំពូកទី ១ បទប្បញ្ញត្តិទូទៅ ........................................ ៣/៣១

ជំពូកទី ២ ក្រុមប្រឹក្សាឃុំ សង្កាត់ ........................................ ៤/៣១

ជំពូកទី ៣ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់ ........................................ ១០/៣១

ជំពូកទី ៤ តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់ ........................................ ១៥/៣១

ជំពូកទី ៥ ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍ ........................................ ១៩/៣១

ជំពូកទី ៦ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ........................................ ២១/៣១

ជំពូកទី ៧ ហិរញ្ញវត្ថុឃុំ សង្កាត់ ........................................ ២៤/៣១

ជំពូកទី ៨ ទោសប្បញ្ញត្តិ ........................................ ២៨/៣១

ជំពូកទី ៩ អន្តរប្បញ្ញត្តិ ........................................ ២៩/៣១

ជំពូកទី ១០ អវសានប្បញ្ញត្តិ ........................................ ៣១/៣១

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល
## ឃុំ សង្កាត់

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖ ៸៷.

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៖.

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

មាត្រា ១១.-

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

មាត្រា ១២.-

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជា-សាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមា-ជិកដទៃទៀតដែរ ។

មាត្រា ១៣.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ញាដូចបានចែងក្នុងបទបញ្ញាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

**មាត្រា ១៤.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

**មាត្រា ១៦.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ៸៸.

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ

- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវចាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះមានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។/.

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

មាត្រា ២២.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើសពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្ដមានុភាព ។

មាត្រា ២៣.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

មាត្រា ២៤.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។/.

# ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម ៖

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប ៖

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប ៖

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិ ឱ្យបានសមស្រប ។ល។

**មាត្រា ៣២.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខ-ជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣៣.-**

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

**មាត្រា ៣៥.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ល។

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្សេងៗតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងចាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬ ចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះ ក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ នឹងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្ដីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្ដល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម ។ល។

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ច ដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤
## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចិរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។៚

**មាត្រា ៤៣.-**

ក្នុងតួនាទីបំពេញកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ
- ប្រៃសណីយ៍និងទូរគមនាគមន៍
- ការពារប្រទេស ...

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសំរុះសំរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។៚

មាត្រា ៤៩.-

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ៥០.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៥១.-

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ល៉ះ

មាត្រា ៥២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះឡើយ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- ប៉ាន់ប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចបំបែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

មាត្រា ៥៤.-

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។៚

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនឹងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតំរូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំលាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

មាត្រា ៥៨.-

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៥៩.-

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

មាត្រា ៦០.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៦១.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

មាត្រា ៦២.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ៕

### មាត្រា ៦៣.-

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

### មាត្រា ៦៤.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ៸.

**មាត្រា ៦៥.-**

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតំរូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសំរួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតំលៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៦៧.-**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

**មាត្រា ៦៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតំលៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៦៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ទាំងឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ./.

៦២ ស៊

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្ងៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។/ៈ

មាត្រា ៧៤.-

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

មាត្រា ៧៥.-

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមានៈ

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ

- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៧៦.-

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។៚

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្តល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្តល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី ៖

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល។

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្ដីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯងនិងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យៗបានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូ[illegible]កឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួនដែលរួមមាន : ៩.ក.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។៸.

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ ន.ប.

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យ១៨ ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្ដីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្ដុះបណ្ដាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិះរកមធ្យោបាយសំរាប់ផ្ដល់ព័ត៌មាននិងគំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្ដល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្ដល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ល.ក.

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៨នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។/.

រាជធានីភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

ស ខេង យូ ហុកគ្រី

លេខ : ៧០ ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ៣ ឆ្នាំ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

# ច្បាប់
# ស្តីពី
# ការបោះឆ្នោតជ្រើសរើស
# ក្រុមប្រឹក្សាឃុំ សង្កាត់ និង
# ច្បាប់ស្តីពីវិសោធនកម្ម
# នៃច្បាប់នេះ

# មាតិកា


| | | | |
|---|---|---|---|
| ជំពូកទី | ១ | បទប្បញ្ញត្តិទូទៅ | ៧/៧៤ |
| ជំពូកទី | ២ | ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | ៨/៧៤ |
| ជំពូកទី | ៣ | ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត | ១០/៧៤ |
| ជំពូកទី | ៤ | ប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសនៈ | ១១/៧៤ |
| ជំពូកទី | ៥ | ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត | ១៧/៧៤ |
| ជំពូកទី | ៦ | ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | ២១/៧៤ |
| ជំពូកទី | ៧ | ការឃោសនាបោះឆ្នោត | ២៩/៧៤ |
| ជំពូកទី | ៨ | ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ | ៣៦/៧៤ |
| ជំពូកទី | ៩ | ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត | ៤០/៧៤ |
| ជំពូកទី | ១០ | ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូល ប្រគល់ ទទួលសម្ភារបោះឆ្នោត | ៤៥/៧៤ |
| ជំពូកទី | ១១ | លទ្ធផលបណ្តោះអាសន្ន លទ្ធផលផ្លូវការ និងការជំទាស់ចំពោះលទ្ធផលនៃការបោះឆ្នោត | ៥៥/៧៤ |
| ជំពូកទី | ១២ | ការបិទការិយាល័យបោះឆ្នោតក្នុងគ្រាមានអាសន្ន | ៦២/៧៤ |
| ជំពូកទី | ១៣ | ការបោះឆ្នោតឡើងវិញ | ៦៤/៧៤ |
| ជំពូកទី | ១៤ | ទោសប្បញ្ញត្តិ | ៦៥/៧៤ |
| ជំពូកទី | ១៥ | អន្តរប្បញ្ញត្តិ | ៧២/៧៤ |
| ជំពូកទី | ១៦ | អវសានប្បញ្ញត្តិ | ៧២/៧៤ |

នស/រកម/១២១៥/ ០១៥

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៥៨/០០៦/២០១៥ កបធ.ច ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/១០១៧/០១២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៩១/០៣១/២០១៧ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រាមួយ..**

មាត្រា ២០ និងមាត្រា ២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៥ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

# ព្រះរាជក្រម

នស/រកម/០៧២៣/០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ROYAUME DU CAMBODGE · CABINET DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

  បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្ដីសម្រេចលេខ២២២/០០៤/២០២៣ កបធ.ច ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

**មាត្រាថ្មី .. វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

មាត្រា៣៥ មាត្រា១៧១ និងមាត្រា១៧២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ច្បាប់នេះមានគោលដៅកំណត់បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ច្បាប់នេះត្រូវអនុវត្តចំពោះឃុំ សង្កាត់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២._**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣._**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់ ០៥ (ប្រាំ) ឆ្នាំ ម្តង ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា ។

កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៩ (ប្រាំបួន) ខែ យ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយថ្ងៃ ។

**មាត្រា ៤._**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកាន់កាប់មុខតំណែងរបស់ខ្លួនរហូតទាល់តែមានក្រុមប្រឹក្សាថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

**មាត្រា ៥._**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែល ៖

-បានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ

-មានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់ ។

អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តែមួយប៉ុណ្ណោះ ។

**មាត្រា ៦.-**

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗដូចបានចែងក្នុងមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យក្នុងរយៈពេលយ៉ាងតិច ០៤ (ប្រាំបួន) ខែមុនថ្ងៃបោះឆ្នោត ។

## ជំពូកទី ២
## ការគ្រប់គ្រងការបោះឆ្នោត
## ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៧ .-**

ការចាត់ចែង រៀបចំ និងគ្រប់គ្រងបញ្ជីបោះឆ្នោត និងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវដាក់ចេញនូវបទបញ្ជា និងនីតិវិធីសម្រាប់ចាត់ចែងរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានអំណាច មុខងារ និងភារកិច្ចដូចខាងក្រោម ៖

-រៀបចំ និងផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត

-ពិនិត្យរៀបចំបញ្ជីបោះឆ្នោតជារៀងរាល់ឆ្នាំ

-ការពារសុវត្ថិភាព និងរក្សាបញ្ជីបោះឆ្នោត

-សម្រេចលើការចុះបញ្ជីបេក្ខជន

-ពិនិត្យតាមដានយុទ្ធនាការឃោសនាបោះឆ្នោត

-គ្រប់គ្រងនីតិវិធីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត

-គ្រប់គ្រងនីតិវិធីរាប់សន្លឹកឆ្នោត និងចាត់ចែងការរាប់សន្លឹកឆ្នោត

-ប្រកាសលទ្ធផលនៃការបោះឆ្នោត

-ការពារសុវត្ថិភាពក្នុងដំណើរការបោះឆ្នោត ដំណើរការរាប់សន្លឹកឆ្នោត និងការពារសុវត្ថិភាពសម្ភារ ឧបករណ៍ គ្រឿងសង្ហារិម សម្រាប់ដំណើរការបោះឆ្នោតទាំងមូល

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

-បណ្តុះបណ្តាលមន្ត្រីបោះឆ្នោត និងណែនាំដល់បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អំពីនីតិវិធីផ្សេងៗសម្រាប់ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ

-ជានាឲ្យសាធារណជនទូទៅ មានការយល់ដឹងអំពីគោលបំណងនៃការបោះឆ្នោត

-ធានាឲ្យជនគ្រប់រូបមានសិទ្ធិចូលរួម ប្រកបដោយសុវត្ថិភាព និងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យក្នុងដំណើរការបោះឆ្នោត

-រៀបចំនីតិវិធីនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ប្រកបដោយតម្លាភាព និងដោយមានការចូលរួមពីអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ

-ធានាឲ្យមានទំនាក់ទំនងទៀងទាត់ រវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាមួយបេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

-អនុវត្តតាមការកំណត់ និងនីតិវិធីផ្សេងៗដែលទាក់ទងដល់ការត្រួតពិនិត្យ ការគ្រប់គ្រង ហិរញ្ញវត្ថុដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សម្រេចលើបណ្តឹងតវ៉ាទាក់ទងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែបណ្តឹងតវ៉ាទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ

-ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភា ស្តីពីការគ្រប់គ្រង ការប្រព្រឹត្តទៅ និងលទ្ធផលនៃការបោះឆ្នោត ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត

-អនុវត្តការងារដទៃទៀតតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

## មាត្រា ១០.-

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលទទួលខុសត្រូវចំពោះការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការងារដទៃទៀត ត្រូវផ្តល់កិច្ចសហការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត និងក្រោយសម័យបោះឆ្នោត ។

## មាត្រា ១១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិតែងតាំងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ឬគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ឬគណៈកម្មការការិយាល័យបោះឆ្នោតក្នុងរយៈពេលមានកំណត់ នៅពេលណាមួយបន្ទាប់ពីការបោះឆ្នោត ក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតឡើងវិញ ឬបោះឆ្នោតសាជាថ្មី ។

## ជំពូកទី ៣
## ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត

**មាត្រា ១២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជានាឲ្យមានបញ្ជីបោះឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដែលបានបង្កើតឡើងតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់នេះ ។

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរ

-មានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត

-មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត

-មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត

-ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។

បែបបទ និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោត ដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានយកមកអនុវត្តដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែមាត្រា ៤៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ១៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ផ្លូវការ ៩០ (កៅសិប) ថ្ងៃយ៉ាងតិច មុនថ្ងៃបោះឆ្នោត។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៤
# ប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសនៈ

**មាត្រា ១៤.-**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ២០ នៃច្បាប់នេះ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសចេញពីក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដែលត្រូវបានជាប់ឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ។

**មាត្រា ១៥.-**

ចំនួនអាសនៈនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវស្មើគ្នានឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ។

**មាត្រា ១៦.-**

អាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោត តាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទីមួយ** : កំណត់ចំនួនកូតាដែលតម្រូវឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈមួយ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបមកចែកនឹងចំនួនអាសនៈសរុបរបស់ក្រុមប្រឹក្សា តាមរូបមន្តដូចខាងក្រោម ៖

$$ក_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ ៖

–$ក_{ត}$ : តាងឲ្យកូតាជាផលចែកដោយមិនគិតសំណល់ចែក

–$ស_{ស}$ : តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឲ្យបញ្ជីបេក្ខជន នៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

–$អ_{ស}$: តាងឲ្យចំនួនអាសនៈសរុបនៅក្នុងក្រុមប្រឹក្សា ។

ជំហានទីពីរ : កំណត់ចំនួនអាសនៈដាបឋម ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលដោយយកចំនួនសន្លឹកឆ្នោតបានការដែលបញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗបានទទួលមកចែកនឹងកូតា តាមរូបមន្តដូចខាងក្រោម ៖

$$\text{អ}_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក}_{\text{ត}}}$$

ក្នុងនោះ ៖

–$\text{អ}_{\text{ទ}}$ : ជាផលចែកដោយមិនគិតសំណល់ចែក តាងឲ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗមានសិទ្ធិទទួលបាន មុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយនៅក្នុងជំហានទីបី

–$\text{ស}_{\text{ប}}$ : តាងឲ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

–$\text{ក}_{\text{ត}}$ : តាងឲ្យកូតាដែលបានកំណត់នៅក្នុងជំហានទីមួយ ។

បន្ទាប់ពីគណនាគ្រប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ក្នុងជំហានទីពីរហើយ ប្រសិនគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពីធ្វើការគណនាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ អាសនៈដែលនៅសល់ទាំងនេះត្រូវផ្តល់ឲ្យទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទីបី ។

**ជំហានទីបី** : អាសនៈដែលនៅសល់ត្រូវបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តដូចខាងក្រោម ៖

$$\text{ម}_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ}_{\text{ទ}}+១}$$

ក្នុងនោះ ៖

–$\text{ម}_{\text{ធ}}$ : តាងឲ្យមធ្យមភាគខ្ពស់បំផុត

–$\text{ស}_{\text{ប}}$ : តាងឲ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

–$\text{អ}_{\text{ទ}}$ : តាងឲ្យចំនួនអាសនៈ ដែលបែងចែកឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។

ក្នុងករណីនៅសល់អាសនៈចំនួនមួយដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្តក្នុងជំហានទីបី សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់អាសនៈនោះត្រូវបែងចែកទៅឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីនៅសល់អាសនៈច្រើនជាងមួយដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តនៅក្នុងជំហានទីបី ហើយអាសនៈចំនួនមួយត្រូវបែងចែកទៅឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត ។ បន្ទាប់មកត្រូវអនុវត្តតាមរូបមន្តនេះម្តងទៀតដោយបង្កើនតម្លៃ អ₀ ចំនួន ១ ចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានទទួលអាសនៈចំនួនមួយក្នុងការអនុវត្តរូបមន្តលើកទីមួយ។ ដូច្នេះអាសនៈចំនួនមួយត្រូវផ្តល់ទៅឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុតក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈ ត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែលដោយបែងចែកម្តងមួយអាសនៈ ជាបន្តបន្ទាប់ រហូតដល់អស់អាសនៈដែលនៅសល់ ។

**មាត្រា ១៧.-**

អ្នកជាប់ឆ្នោតទាំងអស់ ត្រូវបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោត តាមចំនួនស្មើគ្នានឹងចំនួនអាសនៈនៃបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោត តាមការគណនាក្នុងមាត្រា ១៦ នៃច្បាប់នេះ ។

ឈ្មោះអ្នកជាប់ឆ្នោតត្រូវស្រង់តាមលំដាប់លេខរៀងពីលើមកក្រោម តាមបញ្ជីបេក្ខជន នៃគណបក្សនយោបាយជាប់ឆ្នោតនីមួយៗ ។

**មាត្រា ១៨.-**

ឃុំ សង្កាត់ណាដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយគត់ដែលត្រូវបានយល់ព្រមឲ្យចុះបញ្ជី ឃុំ សង្កាត់នោះក៏ត្រូវធ្វើការបោះឆ្នោតដែរ ។

ឈ្មោះបេក្ខជន ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះ តាមលំដាប់លេខរៀងពីលើមកក្រោមរហូតដល់គ្រប់អាសនៈនៅក្នុងក្រុមប្រឹក្សា ។

**មាត្រា ១៩.-**

ឈ្មោះបេក្ខជនណា ដែលបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតក្នុងឃុំ សង្កាត់ និងត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយ បេក្ខជននោះត្រូវលុបឈ្មោះចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។

**មាត្រា ២០.- ថ្មី**

ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ដែលខ្លួនទទួលបាន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៃគណបក្សនយោបាយនោះ លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ ។ ករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈដែលនៅទំនេរនោះ ទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀត ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ក្នុងអំឡុងពេលយ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោត អាចប្រកាសមិនទទួលយកអាសនៈរបស់គណបក្សនយោបាយណាមួយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ នៅឃុំ សង្កាត់ណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ ។

ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈដែលនៅទំនេររបស់គណបក្សនយោបាយ ដែលប្រកាសបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់នីតិវិធីឡើងវិញ ដើម្បីសម្របសម្រួលជាមួយគណបក្សនយោបាយទាំងនោះ ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ តាមជំហានទាំងឡាយដូចខាងក្រោម ៖

ជំហានទីមួយ : កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈទៅតាមករណីដូចខាងក្រោម៖

ទី១.ករណីដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មកចែកជាមួយនឹងចំនួនអាសនៈដែលនៅទំនេរនោះ តាមរូបមន្តដូចខាងក្រោម ៖

$$\text{ក}'_{\text{ត}} = \frac{\text{ស}'_{\text{ស}}}{\text{អ}'_{\text{ប}}}$$

ក្នុងនោះ៖

-ក'ត : តាងឱ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក

-ស'ស : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ

-អ'ប : តាងឱ្យចំនួនអាសនៈរបស់គណបក្សដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ។

ទី២.ករណីដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ មកចែកជាមួយនឹងចំនួនអាសនៈដែលនៅទំនេរនោះ តាមរូបមន្តដូចខាងក្រោម ៖

$$\text{ក}'_{\text{ត}} = \frac{\text{ស}'_{\text{ស}}}{\text{អ}'_{\text{ប}}}$$

ក្នុងនោះ ៖

-ក'ត : តាងឱ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក

-ស'ស : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងដកចេញចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ

-អ'ប : តាងឱ្យចំនួនអាសនៈរបស់គណបក្សនយោបាយដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ។

**ជំហានទីពីរ** : កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល មកចែកនឹងកូតាដែលបានគិតក្នុងជំហានទីមួយ តាមរូបមន្តដូចខាងក្រោម ៖

$$\text{អ}'_{១} = \frac{\text{ស}_{\text{ប}}}{\text{ក}'_{\text{ត}}}$$

ក្នុងនោះ៖

-អ'១ : តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទីបី

-$ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

-$ក'_{ត}$ : តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទីមួយ ។

បន្ទាប់ពីបានធ្វើការគណនាក្នុងជំហានទីពីរ ក្នុងករណីគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទីពីររួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តក្នុងជំហានទីបី ។

**ជំហានទីបី : អាសនៈដែលនៅសល់ត្រូវបានបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម ៖**

$$ម'_{ធ} = \frac{ស_{ប}}{អ'_{ទ}+១}$$

ក្នុងនោះ ៖

-$ម'_{ធ}$ : តាងឱ្យមធ្យមភាគខ្ពស់បំផុត

-$ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

-$អ'_{ទ}$ : តាងឱ្យចំនួនអាសនៈ ដែលបានបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។

វិធីសាស្ត្រដូចមានចែងក្នុងកថាខណ្ឌទី ៧ និងកថាខណ្ឌទី ៨ នៃមាត្រា ១៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទីបី និងការគណនាជាបន្តបន្ទាប់ទៀត ។

## មាត្រា ២១.. ថ្មី

ក្នុងករណីគណនាតាមរូបមន្តដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងមាត្រា ២០ថ្មី នៃច្បាប់នេះ មានលទ្ធផលស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន ដែលមិនអាចកំណត់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបានទទួលអាសនៈដែលត្រូវបែងចែក គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវអនុវត្តវិធីចាប់ឆ្នោត ដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយឈ្នះឆ្នោត ។

វិធីចាប់ឆ្នោតត្រូវដំណើរការតាមនីតិវិធី ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៥
## ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

**មាត្រា ២២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបង្កើតការិយាល័យបោះឆ្នោតមួយ ឬច្រើនសម្រាប់ឃុំ សង្កាត់នីមួយៗស្របតាមបទបញ្ជា និងនីតិវិធីរបស់ខ្លួន ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់ ។

ការិយាល័យបោះឆ្នោត និងតំបន់ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវស្ថិតនៅក្នុងព្រំប្រទល់ឃុំ សង្កាត់របស់ខ្លួន ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតយ៉ាងច្រើន ៧៥០ (ប្រាំពីររយហាសិប) នាក់ ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវប្រមូលផ្តុំដោយភូមិទាំងមូល និងត្រូវបង្កលក្ខណៈឲ្យសមាជិកទាំងអស់របស់គ្រួសារក្នុងភូមិនោះ បានទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយ មានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០ (ប្រាំពីររយហាសិប) នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះទៅក្នុងការិយាល័យបោះឆ្នោតមួយទៀតដែលស្ថិតនៅជិតបំផុតក្នុងឃុំ សង្កាត់ជាមួយ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មី តាមការចាំបាច់ ។

**មាត្រា ២៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិជ្រើសរើសយកបរិវេណ ឬអគារតែមួយធ្វើជាការិយាល័យបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតពីរ ឬច្រើនប្រសិនបើមិនធ្វើឲ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ។

ការិយាល័យបោះឆ្នោតជាច្រើនដែលតាំងនៅបរិវេណ ឬអគារតែមួយនោះ ត្រូវរៀបចំឲ្យស្ថិតនៅដាច់ដោយឡែកពីគ្នា ។

ការិយាល័យបោះឆ្នោតនីមួយៗដែលតាំងនៅបរិវេណ ឬអគារតែមួយនោះ ត្រូវគ្រប់គ្រងឲ្យដាច់ចេញពីគ្នា និងខុសពីការិយាល័យបោះឆ្នោតផ្សេងទៀត ទៅតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាសាធារណៈនូវឈ្មោះទីតាំងនៃ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ការិយាល័យបោះឆ្នោតនីមួយៗ នៅការិយាល័យបោះឆ្នោត និងនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតចាប់តាំងពីកាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជនរហូតដល់ពេលបិទការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ។

**មាត្រា ២៥.-**

ការរាប់សន្លឹកឆ្នោត ត្រូវធ្វើឡើងនៅនឹងការិយាល័យបោះឆ្នោត ។

ការិយាល័យបោះឆ្នោត ជាការិយាល័យរាប់សន្លឹកឆ្នោត ។

ការិយាល័យរាប់សន្លឹកឆ្នោត ជាកន្លែងរាប់សន្លឹកឆ្នោត និងជាកន្លែងប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការរាប់សន្លឹកឆ្នោត ។

គណៈកម្មការការិយាល័យបោះឆ្នោត ក្លាយជាគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

**មាត្រា ២៦.-**

គ្រប់ការិយាល័យបោះឆ្នោត និងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ត្រូវមានបរិវេណខាងក្នុងដែលដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បរិវេណខាងក្នុង ជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត ខណ្ឌដោយវ័ណ្ឌមណ្ឌលមួយដែលមានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ ។

បរិវេណខាងក្នុង ត្រូវរៀបចំឲ្យមានច្រកចូលមួយ និងច្រកចេញមួយ ។

**មាត្រា ២៧.-**

គ្រប់ការិយាល័យបោះឆ្នោត និងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ត្រូវមានបរិវេណខាងក្រៅដែលដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បរិវេណខាងក្រៅ ជាតំបន់ដែលនៅជុំវិញការិយាល័យទាំងនោះ ខណ្ឌដោយវ័ណ្ឌមណ្ឌលមួយដែលមានកាំប្រវែង ១០០ (មួយរយ) ម៉ែត្រ ឬមានទម្រង់ផ្សេង ឬមានកាំតូចជាងស្របទៅតាមស្ថានភាព ជាក់ស្ដែងនៃបរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗនោះ ។

**មាត្រា ២៨.-**

ហាមយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងការស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត ព្រមទាំងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីដែលមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោត

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ មានភារកិច្ចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ ។

**មាត្រា ២៩.-**

ត្រូវបានអនុញ្ញាតឲ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម ៖

-មន្ត្រីបោះឆ្នោត ដែលបានទទួលការចាត់តាំងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ និងដែលបានអនុញ្ញាត និងអ្នកសង្កេតការណ៍ដែលមានប័ណ្ណសម្គាល់ផ្តល់ជូនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ

-ជនដែលអមដំណើរអ្នកបោះឆ្នោតជាជនពិការតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១១៦ នៃច្បាប់នេះ

-ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ធ្វើសំណូមពរក្នុងករណីចាំបាច់ ។

ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត មុនចាប់ផ្តើមការបោះឆ្នោត ឬក្រោយបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣០.-**

ត្រូវបានអនុញ្ញាតឲ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម ៖

-មន្ត្រីរាប់សន្លឹកឆ្នោត ដែលបានទទួលការចាត់តាំងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ភ្នាក់ងារគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះ និងដែលបានអនុញ្ញាត និងអ្នកសង្កេតការណ៍ដែលមានប័ណ្ណសម្គាល់ផ្តល់ឲ្យដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតធ្វើសំណូមពរក្នុងករណីចាំបាច់ ។

ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីគណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោត ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៣១.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មការការិយាល័យបោះឆ្នោត គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ត្រូវចាត់វិធានការចាំបាច់ ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យ រាប់សន្លឹកឆ្នោត និងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ឲ្យចៀសផុតពីការបង្កឲ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារ ឧបករណ៍ សម្ភារទាំងអស់ក្នុងការិយាល័យទាំងនោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មការការិយាល័យបោះឆ្នោត គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតអាចអនុវត្តនូវលក្ខខណ្ឌនៃមាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់នេះ ចំពោះបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ក្នុងករណីចាំបាច់ ដើម្បីធានាឲ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ។

**មាត្រា ៣២.-**

សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

-ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ

-ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឲ្យមនុស្សម្នាក់បោះឆ្នោតឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ

-ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

**មាត្រា ៣៣.-**

សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

-ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ

-ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឲ្យមន្ត្រីរាប់សន្លឹកឆ្នោត រាប់គំនូសនៅលើសន្លឹកឆ្នោត ដើម្បីបំពេញចិត្ត ឬប្រឆាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

**មាត្រា ៣៤.-**

ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតស្របតាមលក្ខខណ្ឌនៃច្បាប់នេះ ។

## ជំពូកទី ៦
## ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ
## សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា៣៥ .- ថ្មី**

ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានបំណងឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

-មានសញ្ជាតិខ្មែរពីកំណើត

-ចេះអាន និងសរសេរអក្សរខ្មែរ

-បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត

-មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលលើកចុងក្រោយដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្រប។ បែបបទ លក្ខខណ្ឌ និងនីតិវិធី ព្រមទាំងមូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះបាន ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ៣៦.-**

ហាមឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ៖

–សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម សមាជិករាជរដ្ឋាភិបាល និងចៅក្រម

–អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

–សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការការិយាល័យបោះឆ្នោត បុគ្គលិកបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់

–មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ ក្នុងមុខតំណែង

–ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ

–ស្មៀនឃុំ សង្កាត់ណាមួយ ។

ROYAUME DU CAMBODGE
LE REGISTRE DU PALAIS ROYAL

**មាត្រា ៣៧.-**

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិដែលមានបំណង ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស យ៉ាងតិច ០៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផល នៃការបោះឆ្នោតជាផ្លូវការ ។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួង ឬសាមី អង្គភាពទៅបម្រើការក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន ក្នុងឋានៈនេះ សាមីខ្លួនត្រូវមាន សិទ្ធិឡើងថ្នាក់ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការ នៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យសាមីក្រសួង ឬសាមីអង្គភាព ជាអ្នកសម្រេច ។

**មាត្រា ៣៨.-**

បន្ទាប់ពីនាយករដ្ឋមន្ត្រីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ផ្សព្វផ្សាយនៅក្នុងឃុំ សង្កាត់នីមួយៗ នូវកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជន និងទីកន្លែង ។

**មាត្រា ៣៩.-**

ជនគ្រប់រូប ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។

បញ្ជីបេក្ខជននីមួយៗ ត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាម លក្ខខណ្ឌ ដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។

បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង ។

**មាត្រា ៤០.-**

បេក្ខជនម្នាក់ៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ ។

**មាត្រា ៤១.-**

ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយត្រូវដាក់ពាក្យ សុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតយ៉ាងតិច ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាង ដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។

**មាត្រា ៤២.-**

ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ ៖

-សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយច្បាប់

-អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការ គណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះអ្នកតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ដែលបានដាក់ស្នើបញ្ជីបេក្ខជន

-បញ្ជីរាយនាមបេក្ខជន ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាក្នុងក្រុមប្រឹក្សាឃុំ សង្កាត់

-នាមត្រកូល និងនាមខ្លួន អាសយដ្ឋាន លិខិតបញ្ជាក់ថាពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត

-ជីវប្រវត្តិសង្ខេបដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ និងរូបថតបេក្ខជនម្នាក់ៗ ចំនួន ០៣ (បី) សន្លឹក ទំហំ ៤ x ៦ ថតចំពីមុខតាមគំរូដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ ។

**មាត្រា ៤៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជនសម្រាប់ឃុំ សង្កាត់នីមួយៗ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជន នៅគ្រប់ទីស្នាក់ការគណៈកម្មការ ឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេល ០៣ (បី) ថ្ងៃ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចេញបង្កាន់ដៃទទួលពាក្យឲ្យគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន និងរក្សាគល់បញ្ជីមួយច្បាប់ទុកជាឯកសារ ។

បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួនឯកសារដែលបានទទួល ចុះកាលបរិច្ឆេទប្រគល់ទទួល និងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ទទួល ។

ROYAUME DU CAMBODGE PALAIS ROYAL

**មាត្រា ៤៤.-**

បន្ទាប់ពីថ្ងៃបញ្ចប់ការទទួលពាក្យសុំចុះបញ្ជីបេក្ខជន គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវធ្វើការពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនទាំងនោះក្នុងរយៈពេល ០១ (មួយ) ថ្ងៃ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន ។

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់មានសិទ្ធិផ្តល់មតិចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបិទផ្សាយខាងលើ មកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

**មាត្រា ៤៥.- ថ្មី**

ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ដែលបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣៥ថ្មី មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤១ និងមាត្រា ៤២ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវសម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននោះ និងចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជន ឲ្យគណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យសុំចុះបញ្ជីបេក្ខជន ។

**មាត្រា ៤៦.- ថ្មី**

ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ដែលបំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣៥ថ្មី មាត្រា៣៦ មាត្រា៣៧ មាត្រា៣៩ មាត្រា៤០ មាត្រា ៤១ និងមាត្រា ៤២ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងណែនាំដល់គណបក្សនយោបាយ ដែលបានដាក់ស្នើបញ្ជីបេក្ខជននោះ ឲ្យធ្វើការកែតម្រូវឲ្យបានត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ ហើយផ្តល់ឱកាសឲ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ។

**មាត្រា ៤៧.-**

ក្នុងករណីគណបក្សនយោបាយ ដែលបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីចំណុចដែលស្នើឲ្យធ្វើការកែតម្រូវ បានធ្វើការកែតម្រូវចំណុចខ្វះខាតបានត្រឹមត្រូវ និងទាន់ពេលវេលា គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជន ហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយនោះ ។

**មាត្រា ៤៨.- ថ្មី**

ក្នុងករណីគណបក្សនយោបាយដែលដាក់ស្នើបញ្ជីបេក្ខជន មិនបានកែតម្រូវចំណុចខ្វះខាតតាមពេលវេលាដូចមានចែងក្នុងមាត្រា៤៦ថ្មី នៃច្បាប់នេះគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតត្រូវបដិសេធពាក្យសុំចុះបញ្ជីបេក្ខជននោះ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវ ៖

-បំពេញទម្រង់បែបបទបដិសេធតាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុជាក់លាក់ នៃការបដិសេធ រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ ជូនដល់សាមីគណបក្សនយោបាយ ឬតំណាងមួយច្បាប់

-ប្រគល់ទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាដល់សាមីគណបក្សនយោបាយ ឬតំណាង

-ផ្ញើទម្រង់បែបបទបដិសេធនោះជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**មាត្រា ៤៩.-**

គណបក្សនយោបាយណាដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយបញ្ជីបេក្ខជននោះត្រូវបានបដិសេធដោយគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត សាមីគណបក្សនយោបាយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ ។

**មាត្រា ៥០.-**

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្រោយពីបានទទួលទម្រង់បែបបទប្តឹងតវ៉ា ។

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវកាលបរិច្ឆេទពេលវេលា និងទីកន្លែងដែលត្រូវបើកសវនាការនោះ ។

**មាត្រា ៥១.-**

ក្នុងករណីគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតយល់ព្រមលើការប្តឹងតវ៉ា គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវចារយល់ព្រម និងចុះហត្ថលេខាលើទម្រង់បែបបទប្តឹងតវ៉ាជូនដល់អ្នកប្តឹងតវ៉ាមួយច្បាប់ និងចម្លងជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះ និងត្រូវចុះបញ្ជីបេក្ខជននោះ ហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនសាមីគណបក្សនយោបាយ ។

## មាត្រា ៥២.-

ក្នុងករណីគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតបដិសេធលើបណ្តឹងតវ៉ា គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវ ៖

-បំពេញទម្រង់បែបបទបដិសេធតាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

-ផ្តល់ទម្រង់បែបបទបដិសេធនោះដល់សាមីគណបក្សនយោបាយ ឬតំណាងមួយច្បាប់ និងចម្លងជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់

-ប្រគល់ទម្រង់បែបបទដល់សាមីគណបក្សនយោបាយ ឬតំណាង សម្រាប់ប្តឹងតវ៉ាទៅគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត

-ផ្ញើទម្រង់បែបបទបដិសេធនោះ ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយច្បាប់ ដើម្បីជ្រាប និងរក្សាទុកជាឯកសារមួយច្បាប់។

## មាត្រា ៥៣.-

គណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយបញ្ជីបេក្ខជននោះត្រូវបានបដិសេធដោយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត សាមីគណបក្សនយោបាយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ ។

## មាត្រា ៥៤.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្រោយពីបានទទួលទម្រង់បែបបទប្តឹងតវ៉ា ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលត្រូវបើកសវនាការនេះ ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសេចក្តីសម្រេចចុងក្រោយ ។

## មាត្រា ៥៥.-

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមលើការប្តឹងតវ៉ា គណៈកម្មាធិការត្រូវចារយល់ព្រម និងចុះហត្ថលេខាលើទម្រង់បែបបទប្តឹងតវ៉ា ជូនអ្នកប្តឹងតវ៉ាមួយច្បាប់ជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ និងទុកជាឯកសារមួយច្បាប់ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

និងត្រូវចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយនោះ ហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនដល់សាមីគណបក្សនយោបាយ ។

**មាត្រា ៥៦.-**

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធបណ្ដឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

-បំពេញទម្រង់បែបបទបដិសេធតាមការកំណត់ រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

-ផ្ដល់ទម្រង់បែបបទបដិសេធនោះ ដល់សាមីគណបក្សនយោបាយ ឬតំណាងមួយច្បាប់ដល់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់

-ផ្ដល់ដំណឹងដល់សាមីគណបក្សនយោបាយ ឬតំណាងថា សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសេចក្ដីសម្រេចចុងក្រោយ ។

**មាត្រា ៥៧.-**

បន្ទាប់ពីបញ្ចប់រយៈពេលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ហើយការប្ដឹងតវ៉ាទាំងអស់ត្រូវបានដោះស្រាយរួចរាល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឲ្យគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួន នូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ។

**មាត្រា ៥៨.-**

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ដូចមានចែងក្នុងមាត្រា ៥៧ នៃច្បាប់នេះ ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ ។

**មាត្រា ៥៩.- ថ្មី**

បណ្ដឹងជំទាស់ត្រូវចោទប្រកាន់ទៅលើបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយដែលបំពេញមិនបានតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣៥ថ្មី មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤១ និងមាត្រា ៤២ នៃច្បាប់នេះ ។

បណ្ដឹងជំទាស់ត្រូវបង្ហាញអំពីបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ជាក់លាក់ណាមួយ ដោយបញ្ជាក់ពីចំណុចខ្វះខាតជាក់ស្ដែងរបស់បេក្ខជន ឬបញ្ជីបេក្ខជននោះ និងហេតុផលដែលស្នើសុំឲ្យច្រានចោលបេក្ខជន ឬបញ្ជីបេក្ខជននោះ ។

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

**មាត្រា ៦០.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្រោយពីបានទទួលបណ្ដឹងជំទាស់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្ដល់ព័ត៌មានដល់គណបក្សនយោបាយ ដែលបានដាក់ស្នើបញ្ជីបេក្ខជនមានការប្ដឹងជំទាស់ ឬតំណាង ផ្ដល់ព័ត៌មានដល់អ្នកប្ដឹងជំទាស់ និងផ្សព្វផ្សាយជាសាធារណៈអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង ដែលត្រូវបើកសវនាការនោះ ។

**មាត្រា ៦១.-**

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រម ឬបដិសេធបណ្ដឹងជំទាស់ណាមួយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

-បំពេញទម្រង់បែបបទតាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការយល់ព្រម ឬបដិសេធលើបណ្ដឹងជំទាស់ រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

-ផ្ដល់ទម្រង់បែបបទនោះដល់អ្នកប្ដឹងជំទាស់មួយច្បាប់ ដល់គណបក្សនយោបាយ ដែលបានដាក់ស្នើបញ្ជីបេក្ខជនហើយមានការប្ដឹងជំទាស់ ឬតំណាងមួយច្បាប់ ដល់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់

-ផ្ដល់ដំណឹងដល់អ្នកប្ដឹងជំទាស់ និងសាមីគណបក្សនយោបាយ ឬតំណាងថា សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសេចក្ដីសម្រេចចុងក្រោយ ។

**មាត្រា ៦២.-**

ក្នុងករណីប្ដឹងជំទាស់ត្រូវបានយល់ព្រម គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបដិសេធបេក្ខភាព ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានការប្ដឹងជំទាស់នោះ រួចហើយលុបបេក្ខភាព ឬបញ្ជីបេក្ខជននោះចេញ ព្រមទាំងដកហូត និងបដិសេធលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជននោះ ។

**មាត្រា ៦៣.-**

បញ្ជីបេក្ខជនដំបូងនឹងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ប្រសិនបើគ្មានបណ្ដឹងជំទាស់មកលើបញ្ជីនេះ ក្នុងរយៈពេលដូចដែលបានកំណត់ក្នុងមាត្រា ៥៨ នៃច្បាប់នេះ ឬការប្ដឹងជំទាស់ត្រូវបានដោះស្រាយស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៦០ មាត្រា ៦១ និង មាត្រា ៦២ នៃច្បាប់នេះ ។

**មាត្រា ៦៤.-**

ផ្អែកលើបញ្ជីបេក្ខជនផ្លូវការដូចមានចែងក្នុងមាត្រា ៦៣ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលត្រូវដាក់លើ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

សន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ទៅគណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោត តាមរយៈគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ។

នីតិវិធីនៃការចាប់ឆ្នោតត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោត ។

**មាត្រា ៦៥.-**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជនក្នុងបញ្ជីនីមួយៗ ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ ។

បញ្ជីបេក្ខជនផ្លូវការ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជននៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

**មាត្រា ៦៦.-**

គណបក្សនយោបាយ និងបេក្ខជននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីជាផ្លូវការ ត្រូវគោរពក្រមសីលធម៌ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៧
## ការឃោសនាបោះឆ្នោត

**មាត្រា ៦៧.-**

ការឃោសនាបោះឆ្នោតមានបំណងឲ្យគណបក្សនយោបាយ ដែលបានអនុញ្ញាតឲ្យចុះបញ្ជីបេក្ខជន និងបេក្ខជន ធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ដល់អ្នកបោះឆ្នោត ។

**មាត្រា ៦៨.-**

ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឲ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ មានដូចជា ៖

-ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន

-ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅឃុំ សង្កាត់ យ៉ាងច្រើន ០២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត

-ការជួបជុំ ឬការឃោសនាតាមផ្ទះ

-ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន

-ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ

-សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា

-សកម្មភាពចែកចាយខិតប័ណ្ណគណបក្សនយោបាយ

-សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬ បេក្ខជន ជូនអ្នកបោះឆ្នោត

-សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទក្រដាសផ្សាយ

-ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត

-ការរៀបចំកម្មវិធីប្រកួតកីឡា ។

**មាត្រា ៦៩.-**

ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ ។

ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយមិនត្រូវបានអនុញ្ញាតឲ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ ។

ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិតប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន ។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទ ស្លាកសញ្ញា បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិតប័ណ្ណរបស់គណបក្សណាមួយបាន ។

ស្លាកសញ្ញាគណបក្សនយោបាយ ឬសម្ភារឃោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការ អចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៧០.-**

ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត ។

ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិអំពីកិច្ចការបោះឆ្នោត ត្រូវអនុវត្តតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ៧១.-**

គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឲ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យ អសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬលើបុគ្គលណាមួយឡើយ ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឲ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយឡើយ ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ។

**មាត្រា ៧២.-**

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវ ៖

-ប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះ ទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ខាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ

-ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឲ្យគណបក្សនយោបាយ ឬបេក្ខជនណាមួយ

-ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយ ឬបេក្ខជនណាមួយឡើយ ។

ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត ដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ដូចតទៅ ៖

- ជាសមាជិកនៃគណៈកម្មការអេចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈ-កម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។
- ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។
- ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោត ដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។
- ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។
- ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗតាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

**មាត្រា ៧៣.-**

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឲ្យមានការគំរាមកំហែងឡើយ ។

**មាត្រា ៧៤.-**

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោម ៖

–ផ្តួចផ្តើម ឬចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្តួចផ្តើម ឬការចូលរួមឃោសនា រួមមាន ៖

- ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឲ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ការចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។

–ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀង រួមមាន ៖

- ការស្ទង់មតិក្នុងគោលបំណងបម្រើឲ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យប្រមាថ មាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

–ផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ដែលរួមមាន ៖

- ការផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋសម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

- ការផ្តល់ថវិកា សម្ភារ និងបរិក្ខារ សម្រាប់ដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

**មាត្រា ៧៥.-**

ហាមជនបរទេសដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

**មាត្រា ៧៦.-**

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ ដែលចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រមសីលធម៌ គោរពតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

របៀប បែបបទប្តឹងជំទាស់ ឬតវ៉ាក្នុងពេលឃោសនាបោះឆ្នោត និងការដោះស្រាយពាក្យបណ្តឹង ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៧៧.-**

កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មាន ដែលស្នើឡើងដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅ នៃការបោះឆ្នោត និងការចាត់ចែងអប់រំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់វិធានការ ដើម្បីផ្សព្វផ្សាយអត្ថបទឃោសនាតាមសំណើរបស់គណបក្សនយោបាយ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ផ្អែកតាមគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយ ។

**មាត្រា ៧៨.-**

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់សម្រាប់ឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការស្នើសុំ ។

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

គណបក្សនយោបាយ ឬបេក្ខជន ដែលមានបំណងជួលរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ត្រូវដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងយ៉ាងហោច ០៣ (បី) ថ្ងៃ មុនថ្ងៃប្រជុំឃោសនា ហើយត្រូវផ្ញើសេចក្ដីចម្លងនៃពាក្យសុំនេះមួយច្បាប់ដល់គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ។

អ្នកគ្រប់គ្រង ត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំមិនឲ្យលើស ២៤ (ម្ភៃបួន) ម៉ោង ក្រោយពីបាន ទទួលពាក្យស្នើសុំ ។

**មាត្រា ៧៩.-**

ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាព ឃោសនាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងការប្រើប្រាស់មធ្យោបាយ ដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

**មាត្រា ៨០.-**

គណបក្សនយោបាយនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ឬបេក្ខជនអាចធ្វើការឃោសនានៅ តាមកន្លែងឯកជនបាន តែត្រូវមានការយល់ព្រមជាមួយម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាមុន ទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតអំពីកាលបរិច្ឆេទនៃការឃោសនាបោះឆ្នោតនោះ ។

**មាត្រា ៨១.-**

គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រមិនត្រូវជ្រៀតជ្រែក ឬធ្វើឲ្យរាំងស្ទះដល់សកម្មភាព របស់គណបក្សនយោបាយបេក្ខជន ឬអ្នកគាំទ្រផ្សេងទៀត ។

**មាត្រា ៨២.-**

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និង វិស័យការងារឯទៀត ត្រូវផ្ដល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការចុះបញ្ជីបេក្ខជនឈរឈ្មោះ បោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះ-ឆ្នោត តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ ។

# ជំពូកទី ៨
# ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

**មាត្រា ៨៣.-**

គណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ មានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួន ០២ (ពីរ) រូប ពេញសិទ្ធិ ០១ (មួយ) រូប និងបម្រុង ០១ (មួយ) រូប ក្នុងចំណោមអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហៅថាភ្នាក់ងារគណបក្សនយោបាយ នៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ដែលខ្លួនឈរឈ្មោះបោះឆ្នោត ។

ភ្នាក់ងារគណបក្សនយោបាយនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតមួយ ត្រូវមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុង ឃុំ សង្កាត់ ។

ភ្នាក់ងារគណបក្សនយោបាយ ត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតែម្នាក់ប៉ុណ្ណោះ ។

ភ្នាក់ងារបម្រុងគណបក្សនយោបាយ ត្រូវអនុញ្ញាតឲ្យជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីភ្នាក់ងារពេញសិទ្ធិអវត្តមាន ។

**មាត្រា ៨៤.-**

គណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារ និងភ្នាក់ងារបម្រុងរបស់ខ្លួនមកគណៈកម្មការ ឃុំ សង្កាត់ រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជន តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៦៥ នៃច្បាប់នេះ ។

ពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាន និងលិខិតបញ្ជាក់ការចុះឈ្មោះបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ និងការិយាល័យបោះឆ្នោតដែលភ្នាក់ងារនោះ ត្រូវបំពេញការងារ ។

**មាត្រា ៨៥.-**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចុះឈ្មោះ ហើយផ្តល់ប័ណ្ណសម្គាល់ដល់ភ្នាក់ងារគណបក្សនយោបាយណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុង មាត្រា ៨៣ និងមាត្រា ៨៤ នៃច្បាប់នេះ ។

ក្នុងករណីភ្នាក់ងារ និងភ្នាក់ងារបម្រុងណាម្នាក់ដែលបំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៨៣ និងមាត្រា ៨៤ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនយោបាយ ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្រោយពីបានទទួលពាក្យស្នើសុំ ។

គណបក្សនយោបាយមានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះភ្នាក់ងារ និងភ្នាក់ងារបម្រុងរបស់ខ្លួនជាថ្មីមួយលើកទៀត ជំនួសឈ្មោះភ្នាក់ងារ និងភ្នាក់ងារបម្រុងដែលបានបដិសេធ មកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពី បានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធ ។

**មាត្រា ៨៦.-**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធិចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍ក្នុងដំណើរការបោះឆ្នោតទាំងមូល ។

**មាត្រា ៨៧.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីនូវ ៖

-ចំនួនអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ

-លក្ខណសម្បត្តិរបស់អ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

**មាត្រា ៨៨.-**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀបចំសុំចុះឈ្មោះជាអ្នកសង្កេតការណ៍ នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅតាមពេលវេលា និងបទបញ្ជា និងនីតិវិធី ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៨៩.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចុះឈ្មោះ និងផ្តល់ប័ណ្ណសម្គាល់ឲ្យអ្នកសង្កេតការណ៍ណាដែលមានលក្ខណសម្បត្តិត្រឹមត្រូវ តាមការកំណត់ ដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩០.-**

ក្នុងករណីអ្នកសង្កេតការណ៍ណាម្នាក់ ដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់ គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ត្រូវបដិសេធឈ្មោះរបស់ជននោះ ជាលាយលក្ខណ៍អក្សរឲ្យទៅសាមី សមាគម

និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានដាក់ពាក្យសុំសង្កេតការណ៍បោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំ ។

**មាត្រា ៩១.-**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាថ្មីមួយលើកទៀត ជំនួសឈ្មោះអ្នកសង្កេតការណ៍ ដែលបានបដិសេធឲ្យមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុង រយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការបដិសេធ ។

**មាត្រា ៩២.-**

ភ្នាក់ងារគណបក្សនយោបាយនីមួយៗដែលទទួលបានការអនុញ្ញាត មានសិទ្ធិមានវត្តមាននៅតាមការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត តាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩៣.-**

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិជំទាស់ ឬតវ៉ា រាល់ការរំលោភទៅលើច្បាប់នេះ ឬលើបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតដែលភ្នាក់ងារនោះបានឃើញផ្ទាល់ ។

**មាត្រា ៩៤.-**

ការជំទាស់ ឬការតវ៉ា ដូចមានចែងក្នុងមាត្រា៩៣ នៃច្បាប់នេះ ត្រូវធ្វើឡើងទៅប្រធានគណៈ-កម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ។

**មាត្រា ៩៥.-**

របៀប បែបបទនៃការជំទាស់ ឬការតវ៉ា ដូចមានចែងក្នុងមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់នេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩៦.-**

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយមិនត្រូវ ៖

-ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត

-រំខាន ឬជ្រៀតជ្រែកដំណើរការបោះឆ្នោត និងដំណើរការរាប់សន្លឹកឆ្នោត

-លើកឡើងនូវការជំទាស់ ឬការតវ៉ាទៅជនណាម្នាក់ក្រៅពីប្រធានគណៈកម្មការ ការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតបានឡើយ

-រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩៧.-**

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត អ្នកសង្កេតការណ៍មិនត្រូវ ៖

-ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត

-រំខាន ឬជ្រៀតជ្រែកដំណើរការបោះឆ្នោត និងដំណើរការរាប់សន្លឹកឆ្នោត

-រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការផ្សព្វផ្សាយដល់គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលទទួលសង្កេតការណ៍បោះឆ្នោតអំពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បទប្បញ្ញត្តិសំខាន់ៗនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងបទបញ្ជា និងនីតិវិធីរបស់ខ្លួន ។

**មាត្រា ៩៩.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាល បរទេស តំណាងប្រទេសនានា និងតំណាងអង្គការអន្តរជាតិឲ្យចូលរួមសង្កេតការណ៍ការបោះឆ្នោត ។

**មាត្រា ១០០.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចតាក់តែងបទបញ្ជាសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី ៩
## ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត

**មាត្រា ១០១.-**

ឃុំ សង្កាត់នីមួយៗ ត្រូវមានសន្លឹកឆ្នោតដោយឡែករបស់ខ្លួន ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្ដល់ជូន ។

**មាត្រា ១០២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាបោះពុម្ពសន្លឹកឆ្នោតគ្រប់ចំនួនសម្រាប់ឃុំ សង្កាត់នីមួយៗនៅលើក្រដាសពណ៌ស ។

**មាត្រា ១០៣.-**

សន្លឹកឆ្នោតនីមួយៗ ត្រូវមានគល់បញ្ជីសន្លឹកឆ្នោត ។

លេខរៀងតាមលំដាប់តគ្នានៃសន្លឹកឆ្នោត ត្រូវបោះនៅលើគល់បញ្ជីសន្លឹកឆ្នោត ។

**មាត្រា ១០៤.-**

សន្លឹកឆ្នោតនីមួយៗ ត្រូវមានសញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ ។

សញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ដែលត្រូវដាក់នៅលើសន្លឹកឆ្នោត ត្រូវដាក់តាមលំដាប់លំដោយ ផ្អែកតាមលទ្ធផល នៃការចាប់ឆ្នោត ដូចមានចែងក្នុងមាត្រា ៦៤ នៃច្បាប់នេះ ។

**មាត្រា ១០៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាផ្ដល់ហិបឆ្នោតឲ្យបានគ្រប់ចំនួន សម្រាប់ឃុំ សង្កាត់នីមួយៗ ។

គ្រប់ហិបឆ្នោតទាំងអស់ត្រូវ ៖

-មានគម្របជាប់មកជាមួយ

-ធានានូវសុវត្ថិភាព ដែលមិនអាចហូតយកសន្លឹកឆ្នោតចេញពីក្នុងហិបបាន ប្រសិនបើមិនបើកគម្រប

-មានសោ ឬឧបករណ៍ផ្សេងទៀតសម្រាប់កិបពេលបិទហិបឆ្នោត

-មានផ្លាកលេខ ឬសញ្ញាសម្គាល់នៅផ្នែកខាងក្រៅយ៉ាងច្បាស់ដែលមិនអាចដូរ ឬលុបបានដោយងាយ ហើយផ្លាកលេខ ឬសញ្ញាសម្គាល់នេះ ត្រូវមានតែមួយគត់សម្រាប់ហិបនោះ និងសម្គាល់បានថា ហិបនោះទាក់ទងទៅនឹងឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតណាមួយ ។

**មាត្រា ១០៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឲ្យមានត្រាសម្ងាត់ជាផ្លូវការគ្រប់ចំនួន និងខុសៗគ្នា សម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ។

ការិយាល័យបោះឆ្នោតមួយ ត្រូវមានត្រាសម្ងាត់ជាផ្លូវការមួយ សម្រាប់បោះនៅលើផ្នែកខាងខ្នងនៃសន្លឹកឆ្នោតនីមួយៗ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងបទបញ្ជា និងនីតិវិធីសម្រាប់ការប្រគល់ ទទួល និងការប្រគល់ត្រឡប់មកវិញ និងធានាឲ្យបាននូវភាពសម្ងាត់នៃត្រានេះ ។

**មាត្រា ១០៧.-**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវប្រគល់សម្ភារបោះឆ្នោតដែលចាំបាច់សម្រាប់បម្រើការបោះឆ្នោតទៅឲ្យការិយាល័យបោះឆ្នោត មិនឲ្យហួសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោង មុនថ្ងៃបោះឆ្នោត ។

ការិយាល័យបោះឆ្នោត ត្រូវត្រួតពិនិត្យ និងចុះហត្ថលេខាលើបង្កាន់ដៃទទួលសម្ភារបោះឆ្នោតទាំងអស់ដែលបានប្រគល់ឲ្យ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតាក់តែងបទបញ្ជាកំណត់អំពីសម្ភារបោះឆ្នោត និងនីតិវិធីសម្រាប់ការប្រគល់ ទទួល និងការប្រគល់ត្រឡប់មកវិញ នូវសម្ភារបោះឆ្នោត និងធានាឲ្យបាននូវភាពសម្ងាត់ និងសន្តិសុខនៃសន្លឹកឆ្នោត ។

**មាត្រា ១០៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឲ្យការិយាល័យបោះឆ្នោតនីមួយៗ មានសម្ភារ ឧបករណ៍ចាំបាច់ ដូចខាងក្រោម ៖

១- បញ្ជីបោះឆ្នោត។

២- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។

៣- ហិបឆ្នោត ។

៤- បន្ទប់សម្ងាត់ ។

៥- ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោត ។

៦- ទឹកជ្រលក់សម្រាប់សម្គាល់ថាបានបោះឆ្នោតហើយ ។

៧- សោ និងប្រដាប់ឃ្នុំ ។

៨- ក្រដាសបែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល ។

៩- ប៊ិចសរសេរដែលមានគុណភាពល្អ ។

១០- ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ ។

១១- ថង់ប្លាស្ទិក ។

១២- សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗទៀត ។

**មាត្រា ១០៩.-**

មុនថ្ងៃបោះឆ្នោត ២៤ (ម្ភៃបួន) ម៉ោង ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវប្រជុំមន្ត្រីទាំងអស់ ដើម្បីពិនិត្យវត្តមាន និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យ សម្ភារ បរិក្ខាបម្រើឲ្យការបោះឆ្នោត ។

ក្នុងករណីបើមានមន្ត្រីណាម្នាក់អវត្តមាន មន្ត្រីនោះត្រូវជំនួសដោយមន្ត្រីថ្មីដែលជ្រើសតាំងឡើងស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ការ ដើម្បីឲ្យការិយាល័យបោះឆ្នោត មានសម្ភារ បរិក្ខារ និងសង្ហារិមចាំបាច់ សម្រាប់ការបោះឆ្នោត ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោត ហើយចាត់វិធានការការពារសន្តិសុខ បើចាំបាច់ ។

**មាត្រា ១១០.-**

នៅថ្ងៃបោះឆ្នោតមន្ត្រីការិយាល័យបោះឆ្នោតគ្រប់រូបដែលទទួលបានការតែងតាំងឲ្យបំពេញការងារតាមការិយាល័យបោះឆ្នោត ត្រូវមានវត្តមានក្នុងការិយាល័យនៅម៉ោង ៦:០០ នាទី ដោយនាំមកជាមួយនូវសម្ភារ បរិក្ខារបោះឆ្នោតទាំងអស់ ។

ចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានអនុញ្ញាតឲ្យចូលក្នុងការិយាល័យបោះឆ្នោតនៅម៉ោង ៦:០០ នាទី ។

**មាត្រា ១១១.-**

នៅចន្លោះពីម៉ោង ៦:០០ នាទី ដល់ម៉ោង ៦:៣០ នាទី នៅថ្ងៃបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត ត្រូវរៀបចំកិច្ចការ ដូចខាងក្រោម ៖

–ពិនិត្យឡើងវិញនូវហិបឆ្នោតដែលបានផ្តល់ឲ្យ និងពិនិត្យស្លាកលេខ ឬសញ្ញាសម្គាល់ហិបឆ្នោតឲ្យបានត្រឹមត្រូវ

–បង្ហាញអ្នកនៅក្នុងការិយាល័យបោះឆ្នោតថា ហិបឆ្នោតនីមួយៗពុំមានអ្វីក្នុងនោះឡើយ

–បិទគម្របក្នុងនៃហិបឆ្នោត ហើយចាក់សោឃ្លុំ

–បិទស្លាកលេខ ឬសញ្ញាសម្គាល់ជាប់នឹងហិបឆ្នោត ដោយមានបោះត្រារបស់ការិយាល័យបោះឆ្នោតពីលើ

–អនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត ស្លាកលេខ ឬសញ្ញាសម្គាល់ផ្សេងៗដែលបិទលើហិបឆ្នោត ។

ក្នុងករណីសម្ភារ ឧបករណ៍បោះឆ្នោតត្រូវបានប្រគល់ឲ្យការិយាល័យបោះឆ្នោតក្រោយម៉ោង ៦:៣០ នាទី ពេលទទួល ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវអនុវត្តតាមនីតិវិធីខាងលើ

ករណីនេះប្រធានគណៈកម្មការការិយាល័យបោះឆ្នោតអាចពន្យារការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះជាបណ្ដោះអាសន្ន រហូតដល់ពេលដែលនីតិវិធីខាងលើបានបំពេញរួចរាល់ ។

បន្ទាប់ពីបានបិទស្លាកលេខ ឬសញ្ញាសម្គាល់លើហិបឆ្នោតរួចហើយ ហិបឆ្នោតទាំងនេះមិនអាចបើកចំហឡើយ លើកលែងតែក្នុងបំណងរាប់សន្លឹកឆ្នោតដូចមានចែងនៅក្នុងច្បាប់នេះ និងមិនអាចយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែការដឹកជញ្ជូនទៅកន្លែងរាប់សន្លឹកឆ្នោត ក្នុងករណីដែលច្បាប់ ឬបទបញ្ជាតម្រូវឲ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ។

**មាត្រា ១១២.-**

នៅចន្លោះពីម៉ោង ៦:៣០ នាទី ដល់ម៉ោង ៧:០០ នាទី ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់ឲ្យបើកស្រោមសំបុត្រ ដែលមានត្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រាប់សន្លឹកឆ្នោត និងកត់ត្រាចំនួន ព្រមទាំងលេខរៀងនៅលើគល់បញ្ជីសន្លឹកឆ្នោតតាមបែបបទ ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១១៣.-**

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបើកការិយាល័យបោះឆ្នោត នៅម៉ោង ៧:០០ នាទី ។

**មាត្រា ១១៤.-**

អ្នកដែលមានសិទ្ធិចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោតបាន លុះត្រាតែជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយជននោះមិនទាន់បានបោះឆ្នោតនៅឡើយ ។

អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបានផ្ដល់សន្លឹកឆ្នោតឲ្យក្នុងការិយាល័យបោះឆ្នោត ក្នុងករណីដែលអ្នកបោះឆ្នោតនោះបំពេញបានតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ដែលសាមីខ្លួនត្រូវបោះឆ្នោត
- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- មិនទាន់បានបោះឆ្នោតនៅឡើយ ហើយអនុញ្ញាតឲ្យមន្ត្រីបោះឆ្នោតពិនិត្យមើលម្រាមដៃរបស់បុគ្គលនោះ ។

អ្នកបោះឆ្នោតម្នាក់ៗ ត្រូវគូសនៅលើសន្លឹកឆ្នោតតែម្នាក់ឯងនៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយខ្សែក ហើយដាក់សន្លឹកឆ្នោតដែលបានគូសរួចនោះទៅក្នុងហិបឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវអនុញ្ញាតឲ្យមន្ត្រីការិយាល័យបោះឆ្នោតជ្រលក់ទឹកខ្មៅលុបមិនជ្រះ ទៅតាមនីតិវិធីដែលបានកំណត់ ។

របៀបគូសសន្លឹកឆ្នោត និងដាក់សន្លឹកឆ្នោតចូលក្នុងហិបឆ្នោត ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងបទបញ្ជា និងនីតិវិធី ដើម្បីអនុវត្តជាក់ស្តែងនូវមាត្រានេះ និងកំណត់អំពីការគ្រប់គ្រងនីតិវិធីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ។

**មាត្រា ១១៥.-**

អ្នកបោះឆ្នោតដែលបានធ្វើឲ្យខូចសន្លឹកឆ្នោតដោយអចេតនា ត្រូវប្រគល់សន្លឹកឆ្នោតនេះឲ្យមន្ត្រីការិយាល័យបោះឆ្នោត ហើយមន្ត្រីការិយាល័យបោះឆ្នោតត្រូវប្រគល់សន្លឹកឆ្នោតថ្មីមួយជំនួសវិញ ទៅតាមនីតិវិធី ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១១៦.-**

អ្នកបោះឆ្នោតដែលពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនទៅជាមួយ ឬមានសិទ្ធិស្នើសុំជំនួយពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ។

**មាត្រា ១១៧.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតាក់តែងបទបញ្ជាសម្រាប់ការពារសិទ្ធិដល់អ្នកបោះឆ្នោតដែលពិការរាងកាយ ហើយមិនអាចជ្រលក់ទឹកខ្មៅលុបមិនជ្រះបាន ។

**មាត្រា ១១៨.-**

មិនអនុញ្ញាតឲ្យជនណាម្នាក់ចូលទៅជ្រៀតជ្រែក ឬជួយអ្នកបោះឆ្នោតក្នុងពេលដែលអ្នកបោះឆ្នោតស្ថិតនៅក្នុងបរិវេណខាងក្នុង ឬក្នុងការិយាល័យបោះឆ្នោតបានឡើយ លើកលែងតែមានការអនុញ្ញាតអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១១៩.-**

មន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ មានសិទ្ធិប្តឹងជំទាស់ចំពោះជនណាម្នាក់នៅក្នុងការិយាល័យបោះឆ្នោត ក្នុងករណីដែលជននោះមិនបានបំពេញតាមលក្ខខណ្ឌណាមួយដូចមានចែងក្នុងមាត្រា១១៤ នៃច្បាប់នេះ។

ការប្តឹងជំទាស់ត្រូវធ្វើទៅកាន់ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ។

ក្នុងករណីប្រធានគណៈកម្មការការិយាល័យបោះឆ្នោតពិនិត្យឃើញថា ជននោះមិនបានបំពេញតាមលក្ខខណ្ឌណាមួយដូចមានចែងក្នុងមាត្រា ១១៤ នៃច្បាប់នេះ ជននោះមិនត្រូវបានអនុញ្ញាតឲ្យបោះឆ្នោតឡើយ ហើយជននោះត្រូវអមដំណើរដោយមន្ត្រីការិយាល័យបោះឆ្នោត ឲ្យចេញក្រៅពីការិយាល័យបោះឆ្នោត និងពីបរិវេណខាងក្នុង ។

ក្នុងករណីប្រធានគណៈកម្មការការិយាល័យបោះឆ្នោតសម្រេចថា ជននោះបានបំពេញលក្ខខណ្ឌតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ១១៤ នៃច្បាប់នេះ ជននោះ ត្រូវបានអនុញ្ញាត ឲ្យបោះឆ្នោត ។

សេចក្តីសម្រេចរបស់ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ជាសេចក្តីសម្រេចចុងក្រោយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីនូវរបៀបរបប ប្តឹងជំទាស់ ការដោះស្រាយ និងការកត់ត្រា អំពីករណីខាងលើនេះ ។

**មាត្រា ១២០.-**

ក្នុងករណីដែលភ្នាក់ងារគណបក្សនយោបាយ បានយល់ឃើញថាការបោះឆ្នោតមិនប្រក្រតី ភ្នាក់ងារគណបក្សនយោបាយនោះអាចប្តឹងជំទាស់ ឬតវ៉ាមកប្រធានគណៈកម្មការ ការិយាល័យបោះឆ្នោតបាន ។

របៀបរបបបទប្តឹងជំទាស់ ឬតវ៉ា ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវដោះស្រាយបណ្តឹងជំទាស់ ឬតវ៉ានេះ ។

ការសម្រេចរបស់គណៈកម្មការការិយាល័យបោះឆ្នោត ជាការសម្រេចបានការក្នុង កម្រិតសមត្ថកិច្ចរបស់ខ្លួន ប្រសិនបើការបោះឆ្នោតនោះប្រព្រឹត្តទៅដោយប្រក្រតី ។

ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ា គណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះបណ្តឹងជំទាស់ ឬតវ៉ានេះក្នុងកំណត់ហេតុ ដោយឲ្យអ្នកជំទាស់ ឬតវ៉ានោះចុះហត្ថលេខាជាមួយ ។

## ជំពូកទី ១០
## ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូល ប្រគល់ ទទួលសម្ភារបោះឆ្នោត

**មាត្រា ១២១.-**

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោង ១៥:០០ នាទី ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតឲ្យចូលទៅក្នុងបរិវេណខាងក្នុង ក្រោយម៉ោង ១៥:០០ នាទីបានឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោង ១៥:០០ នាទី ហើយអាចអនុញ្ញាតឲ្យបោះឆ្នោត គឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុង នៅម៉ោង ១៥:០០ នាទី ។

**មាត្រា ១២២.-**

បន្ទាប់ពីប្រកាសបិទការបោះឆ្នោត និងក្រោយពីអ្នកបោះឆ្នោតគ្រប់រូប បានបោះឆ្នោតហើយភ្លាម នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវ ៖

-បិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត គ្រប់ហិបឆ្នោតទាំងអស់ ដោយមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយ លើក្រដាសបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតនោះ រួចហើយបិទគម្របខាងក្រៅពីលើ និងចាក់សោហើយអនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោតទាំងនោះ

-ចុះក្នុងកំណត់ហេតុនូវអ្នកដែលបានមកបោះឆ្នោត

-បំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទដោយបង្ហាញពីចំនួនសន្លឹកឆ្នោត ដែលបានទទួល ដែលបានផ្តល់ឲ្យអ្នកបោះឆ្នោត សន្លឹកឆ្នោតដែលខូច ឬដែលបានដកហូតនៅក្នុងការិយាល័យបោះឆ្នោត

-បំបែកគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ចេញពីគល់បញ្ជីសន្លឹកឆ្នោតដែលមិនបានប្រើប្រាស់

-បង្ហាញទម្រង់បែបបទខាងលើដែលបានបំពេញ និងចុះហត្ថលេខារួចហើយ ជូនភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ។

ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើកំណត់ហេតុខាងលើនេះ ។

**មាត្រា ១២៣.-**

សន្លឹកឆ្នោតត្រូវរាប់នៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ ។

ចំពោះការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបានដោយករណីប្រធានសក្តិ ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនឹងធ្វើការណែនាំដោយឡែក ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំ និងគ្រប់គ្រងការិយាល័យរាប់សន្លឹកឆ្នោតស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ១២៤.-**

មន្ត្រីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ជាអ្នកទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោតក្នុងការិយាល័យរបស់ខ្លួន ក្នុងករណីនេះការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត ។

ក្នុងករណីសន្លឹកឆ្នោត ត្រូវរាប់នៅកន្លែងផ្សេងក្រៅពីការិយាល័យបោះឆ្នោតតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៣ នៃច្បាប់នេះ គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតត្រូវចាត់ឲ្យមន្ត្រីការិយាល័យបោះឆ្នោតនោះរាប់សន្លឹកឆ្នោត ឬអាចតែងតាំងមន្ត្រីផ្សេងទៀតឲ្យរាប់សន្លឹកឆ្នោត ក្នុងករណីមន្ត្រីការិយាល័យបោះឆ្នោតនោះ អវត្តមាន ។

**មាត្រា ១២៥.-**

ជនគ្រប់រូបនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុង ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត តាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១២៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឲ្យមានឧបករណ៍ចាំបាច់មួយចំនួន ក្នុងការិយាល័យរាប់សន្លឹកឆ្នោត មាន តុ និងកៅអី គ្រប់គ្រាន់សម្រាប់មន្ត្រីរាប់សន្លឹកឆ្នោត ។

ការរាប់សន្លឹកឆ្នោត ត្រូវធ្វើតែមួយកន្លែង សម្រាប់ការិយាល័យបោះឆ្នោតមួយ ។

ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឲ្យស្ថិតនៅទីជិត ល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត ។

**មាត្រា ១២៧.-**

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត ដែលមាននៅក្នុងហិបឆ្នោតជាមួយចំនួនអ្នកដែលបានមកបោះឆ្នោត ដែលរាប់ឃើញក្នុងបញ្ជីបោះឆ្នោត ។

ក្នុងករណីដែលសន្លឹកឆ្នោតក្នុងហិបឆ្នោត មានចំនួនខុសគ្នានឹងចំនួនអ្នកបោះឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់ឲ្យរាប់ឡើងវិញ ។

ប្រសិនបើចំនួនខុសគ្នានៅតែមានដដែល ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចុះក្នុងកំណត់ហេតុ ។

មុននឹងចាប់ផ្តើមរាប់សន្លឹកឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើប្រាស់ទាំងអស់ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើរួចត្រូវដាក់សន្លឹកឆ្នោតមោឃភាព និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើទៅក្នុងស្បោងផ្លាស្ទិកតែមួយរួចបិទឲ្យជិត ។

បន្ទាប់មកប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់ឲ្យរាប់សន្លឹកឆ្នោត ដោយអនុលោមតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បន្ទាប់ពីបំពេញបែបបទតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១២២ មាត្រា ១២៣ និងមាត្រា ១២៤ នៃច្បាប់នេះ ប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតត្រូវចាត់ឲ្យបើកហិបឆ្នោត និងចាក់សន្លឹកឆ្នោតទាំងអស់ចេញពីក្នុងហិបឆ្នោតនីមួយៗ រួចហើយត្រូវ ៖

-ដាក់វត្ថុដែលមិនមែនជាសន្លឹកឆ្នោតដាច់ដោយឡែក ប្រសិនបើមាន

-លាសន្លឹកឆ្នោតដែលមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង ដោយដាក់ផ្កាប់ចុះក្រោមនៅ

រំនូតទី ១

-ក្នុងករណីមានសន្លឹកឆ្នោតដែលបានបោះ តែមិនមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង ត្រូវដាក់ដោយឡែកនៅពំនូកទី ២

-រាប់ចំនួនសន្លឹកឆ្នោតដែលផ្កាប់ចុះក្រោមទាំងពីរពំនូក ហើយកត់ត្រា និងបង្ហាញអំពីចំនួនសន្លឹកឆ្នោតដែលបានរាប់ទាំងពីរពំនូកដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

ប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ត្រូវផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានរាប់ពីហិបឆ្នោត ជាមួយនឹងចំនួនដែលបានកត់ត្រាក្នុងទម្រង់បែបបទ ដែលបានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១២២ នៃច្បាប់នេះ រួចហើយត្រូវបង្ហាញលទ្ធផល នៃការផ្ទៀងផ្ទាត់នេះដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីឲ្យអ្នកទាំងនោះអាចពិនិត្យ តាមដាន និងវាយតម្លៃលទ្ធផលនោះបាន ។

**មាត្រា ១២៨.-**

មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត ត្រូវផ្ងារសន្លឹកឆ្នោតដែលមានបោះត្រាខាងខ្នងនៅពំនូកទី ១ ដូចមានចែងក្នុងមាត្រា ១២៧ នៃច្បាប់នេះ រួចហើយត្រូវបំបែកសន្លឹកឆ្នោតទាំងនេះជាសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

ត្រូវចាត់ទុកជាបានការ សន្លឹកឆ្នោតណាដែលមានគូសសញ្ញាគាំទ្រគណបក្សនយោបាយ តែមួយនៅលើសន្លឹកឆ្នោតដែលគណៈកម្មការការិយាល័យបោះឆ្នោតចែកឲ្យ ។

ត្រូវទុកជាមោឃៈសន្លឹកឆ្នោត ៖

១-ដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ ឬ

២-ដែលគ្មានគំនូស ឬមានគំនូស តែគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតពុំអាចសន្និដ្ឋានបានថាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយ ឬ

៣-ដែលមានសញ្ញាដែលនាំឲ្យគេស្គាល់អ្នកបោះឆ្នោត ឬ

៤-ដែលមានរហែក ឬខូច ឬ

៥-ដែលគ្មានត្រាសម្ងាត់ជាផ្លូវការ ។

សន្លឹកឆ្នោតដែលទុកជាមោឃៈក្នុងចំណុចទី ១ ទី ២ ទី ៣ ទី ៤ ទី ៥ ខាងលើនេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បន្ទាប់មក មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតត្រូវរាប់សន្លឹកឆ្នោតបានការ ដែលបានគូសសញ្ញាគាំទ្រគណបក្សនយោបាយនីមួយៗ ។

សន្លឹកឆ្នោតត្រូវរាប់ទៅតាមវិធីមួយ ដែលអាចមើលឃើញគំនូសនៃការបោះឆ្នោតទាំងអស់ដោយភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

**មាត្រា ១២៩.-**

នៅពេលមានការជំទាស់ចំពោះសន្លឹកឆ្នោត ដែលបានរាប់តាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១២៨ នៃច្បាប់នេះ សន្លឹកឆ្នោតដែលមានការជំទាស់នោះ ត្រូវដាក់ដាច់ដោយឡែក ហើយដោះស្រាយទៅតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

**មាត្រា ១៣០.-**

មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតត្រូវពិនិត្យមើលគ្រប់សន្លឹកឆ្នោតមិនបានការ និងសន្លឹកឆ្នោតដែលមានការជំទាស់ តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១២៨ និងមាត្រា ១២៩ នៃច្បាប់នេះ ។

ការពិនិត្យសន្លឹកឆ្នោតនេះ ត្រូវធ្វើជាចំហចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ និងសុំឲ្យអ្នកទាំងនោះផ្ដល់មតិយោបល់ ។

បន្ទាប់ពីបានពិចារណាលើមតិយោបល់ទាំងនេះហើយ មន្ត្រីរាប់សន្លឹកឆ្នោតដែលបានទទួលការតែងតាំង ត្រូវសម្រេចបដិសេធចោល និងមិនរាប់សន្លឹកឆ្នោត ដែល ៖

-ពុំមែនជាសន្លឹកឆ្នោតដែលផ្ដល់ឲ្យដោយការិយាល័យបោះឆ្នោត

-គ្មានត្រាសម្ងាត់ជាផ្លូវការ

-គូសឲ្យបញ្ជីគណបក្សនយោបាយលើសពីមួយ

-គ្មានគំនូស

-មានគំនូស ប៉ុន្តែមិនអាចយកជាការបាន ដោយគំនូសនោះមិនអាចឲ្យមន្ត្រីរាប់សន្លឹកឆ្នោតសម្រេចថា តើគូសឲ្យបញ្ជីគណបក្សនយោបាយណាមួយ

-មានសញ្ញាដែលនាំឲ្យគេស្គាល់អ្នកបោះឆ្នោត

-រហែក ឬខូចមិនអាចយកជាការបាន។

សន្លឹកឆ្នោតដែលបានសម្រេចទទួលយកតាមមាត្រានេះ ត្រូវយកមករាប់បូកជាមួយនឹងសន្លឹកឆ្នោតបានការ ដែលបានរាប់តាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃមាត្រា ១២៨ នៃច្បាប់នេះ ទោះបីជាមាន ឬគ្មានការជំទាស់ទៅនឹងការសម្រេចទទួលយកនោះក្ដី ។

**មាត្រា ១៣១.-**

បន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១២៧ មាត្រា ១២៨ មាត្រា ១២៩ និងមាត្រា ១៣០ នៃច្បាប់នេះ ប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតត្រូវធ្វើកំណត់ហេតុស្ដីពីលទ្ធផល បណ្ដោះអាសន្ននៃការរាប់សន្លឹកឆ្នោត សម្រាប់ការិយាល័យរបស់ខ្លួនទៅតាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រួចផ្ញើជូនគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតដែលពុំបានប្រើប្រាស់ ពាក្យបណ្ដឹងជំទាស់ ឬតវ៉ា ប្រសិនបើមាន និងឯកសារផ្សេងៗ បិទនៅការិយាល័យបោះឆ្នោត និងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ។

ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើកំណត់ហេតុខាងលើនេះ ។

កំណត់ហេតុស្តីពីលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតនោះ ត្រូវកត់ត្រាចំនួនសន្លឹកឆ្នោតដែលបានរាប់ពីហិបឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានបដិសេធចោលមិនបានរាប់ ចំនួនសន្លឹកឆ្នោតបានការដែលបានរាប់ ចំនួនសន្លឹកឆ្នោតខូច ចំនួនសន្លឹកឆ្នោតនៅសល់ និងចំនួនសន្លឹកឆ្នោតដែលបានបោះឲ្យបញ្ជីបេក្ខជននីមួយៗទៅតាមលំដាប់ឈ្មោះ នៅលើសន្លឹកឆ្នោត ។

កំណត់ហេតុស្តីពីលទ្ធផលបណ្តោះអាសន្ន នៃការរាប់សន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវស្ថិតក្រោមការត្រួតពិនិត្យឡើងវិញ ដោយគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់លើ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៣២.-**

កំណត់ហេតុស្តីពីការរាប់សន្លឹកឆ្នោតដូចមានចែងក្នុងមាត្រា ១៣១ នៃច្បាប់នេះ ត្រូវធ្វើជា ០៣ (បី) ច្បាប់ ៖

-មួយច្បាប់ផ្ញើជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដោយភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះអ្នកបោះឆ្នោត គល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតពុំបានការ សន្លឹកឆ្នោតខូច ហិបឆ្នោត ត្រាសម្ងាត់សម្រាប់ការិយាល័យបោះឆ្នោត បណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាន និងឯកសារ សម្ភារ ឧបករណ៍ចាំបាច់ផ្សេងៗទៀត ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

សម្ភារ ឧបករណ៍ និងឯកសារខាងលើនេះត្រូវរៀបចំ ឬច្រកក្នុងស្រោមសំបុត្រ ដោយឡែកៗពីគ្នា តាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

-មួយច្បាប់បិទផ្សាយជាសាធារណៈនៅការិយាល័យរាប់សន្លឹកឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត

-មួយច្បាប់ទៀតបិទផ្សាយជាសាធារណៈនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំ-ការបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

**មាត្រា ១៣៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ឲ្យបានជាក់ស្តែងបន្ថែមទៀត នូវ ៖

-នីតិវិធីស្តីពីការរាប់សន្លឹកឆ្នោត

-សេចក្តីណែនាំសម្រាប់ធ្វើកំណត់ហេតុពេលរាប់សន្លឹកឆ្នោត ក្នុងការិយាល័យរាប់សន្លឹកឆ្នោត

-របៀបប្រមូលផ្តុំ វេចខ្ចប់ និងរាយមុខសម្ភារបោះឆ្នោតឲ្យបានត្រឹមត្រូវសម្រាប់ការប្រគល់គ្នាទទួលផង និងរាយការណ៍ដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

-នីតិវិធីសម្រាប់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រួតពិនិត្យកំណត់ហេតុរាប់សន្លឹកឆ្នោត បូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យរាប់សន្លឹកឆ្នោត និងការត្រួតពិនិត្យឧបករណ៍ សម្ភារបោះឆ្នោតដែលបានទទួលពីគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ។

## មាត្រា ១៣៤.-

ក្នុងករណីមានការសម្រេចពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឲ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេងពីការិយាល័យបោះឆ្នោត ការរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេងនោះត្រូវអនុវត្តទៅតាមនីតិវិធីដូចមានចែងក្នុងមាត្រា ១២៧ មាត្រា ១២៨ មាត្រា ១២៩ មាត្រា ១៣០ មាត្រា ១៣១ មាត្រា ១៣២ និងមាត្រា ១៣៣ នៃច្បាប់នេះ ។

## មាត្រា ១៣៥.-

បន្ទាប់ពីបានបំពេញកំណត់ហេតុរាប់សន្លឹកឆ្នោត និងប្រមូលសម្ភារបោះឆ្នោតរួចរាល់ហើយ មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតត្រូវនាំយកកំណត់ហេតុ និងសម្ភារបោះឆ្នោតទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានអនុញ្ញាតចូលរួមក្នុងការដឹកជញ្ជូនការប្រគល់ និងការទទួលកំណត់ហេតុរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារបោះឆ្នោតខាងលើនេះ ។

## មាត្រា ១៣៦.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវមានវត្តមាននៅទីស្នាក់ការរបស់ខ្លួន ដើម្បីរង់ចាំទទួលកំណត់ហេតុរាប់សន្លឹកឆ្នោត និងសម្ភារបោះឆ្នោតពីគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ចាប់ពីម៉ោង ១៥:០០ នាទី រហូតដល់បានទទួលកំណត់ហេតុរាប់សន្លឹកឆ្នោត និងសម្ភារបោះឆ្នោតពីគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ចំណុះឃុំ សង្កាត់របស់ខ្លួន ។

នៅពេលគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតទទួលកំណត់ហេតុរាប់សន្លឹកឆ្នោត និងសម្ភារបោះឆ្នោតទាំងអស់ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចុះហត្ថលេខាលើទម្រង់បែបបទប្រគល់ ទទួល រួចហើយប្រគល់ជូនប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតមួយច្បាប់ និងទុកជាឯកសារមួយច្បាប់ ។

ទម្រង់បែបបទប្រគល់ទទួលខាងលើនេះ អាចឲ្យភ្នាក់ងារគណបក្សនយោបាយ ចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី ។

## មាត្រា ១៣៧.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យ និងបូកសរុបលទ្ធផល បណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត តាមការិយាល័យរាប់សន្លឹកឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលកំណត់ហេតុនៃការបោះឆ្នោត និងសម្ភារបោះឆ្នោតពីគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ ។

ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មិនអាចបើកកញ្ចប់សន្លឹកឆ្នោត និងមិនអាចរាប់សន្លឹកឆ្នោតឡើងវិញបានឡើយ ចំពោះការិយាល័យរាប់សន្លឹកឆ្នោតណាដែលគ្មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ អំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ។

ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារបោះឆ្នោតដែលបានប្រមូលមកពីគ្រប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ១៣៨.–**

កំណត់ហេតុរាប់សន្លឹកឆ្នោត និងសម្ភារបោះឆ្នោតដែលបានទទួលពីការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ត្រូវកត់ចំណាំ និងទុកដាក់ដោយឡែក តាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះ-អាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួនទៅតាមទម្រង់បែបបទដែលកំណត់ ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

កំណត់ហេតុខាងលើនេះត្រូវធ្វើជា ០៣ (បី) ច្បាប់ ៖

–មួយច្បាប់ផ្ញើជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដោយភ្ជាប់ជាមួយនូវបញ្ជីឈ្មោះអ្នកបោះឆ្នោត គល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើសន្លឹកឆ្នោតមិនបានប្រើសន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតខូច ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោត ពាក្យបណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាន ព្រមទាំងសម្ភារ ឯកសារផ្សេងៗទៀត

–មួយច្បាប់ទៀតបិទនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត

–មួយច្បាប់ទុកជាឯកសារ ។

**មាត្រា ១៣៩.–**

ក្នុងករណីមានបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ាអំពីភាពមិនប្រក្រតី ដែលអាចប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យនោះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដោយ ៖

–ពិនិត្យលេខរៀងគល់បញ្ជីសន្លឹកឆ្នោត ដែលបានប្រគល់ឲ្យការិយាល័យបោះឆ្នោតជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោត ដែលទទួលពីការិយាល័យនោះមកវិញ

–ពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានមកបោះឆ្នោត

-ពិនិត្យ និងរាប់សន្លឹកឆ្នោតបានការដែលបានបោះឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ

-ពិនិត្យសន្លឹកឆ្នោតមិនបានការ

-រាប់សន្លឹកឆ្នោតខូច

-រាប់សន្លឹកឆ្នោតដែលមិនបានប្រើប្រាស់

-ពិនិត្យមើលត្រាសម្ងាត់ជាផ្លូវការ ដែលបានប្រគល់ដល់ការិយាល័យបោះឆ្នោតនោះ

-ពិនិត្យមើលហិបឆ្នោត និងសញ្ញាសម្គាល់ ឬលេខសម្គាល់ហិបឆ្នោតរបស់ការិយាល័យបោះឆ្នោតនោះ ផ្ទៀងផ្ទាត់ជាមួយសញ្ញាសម្គាល់ ឬលេខសម្គាល់ហិបឆ្នោតដែលបានប្រគល់ដល់ការិយាល័យបោះឆ្នោតនោះ ។

សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតខូចត្រូវចងជាដុំៗតាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បន្ទាប់ពីការត្រួតពិនិត្យខាងលើនេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវធ្វើសេចក្តីរាយការណ៍ និងលើកយោបល់ភ្ជាប់ជាមួយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះ-ឆ្នោតជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដើម្បីពិនិត្យ និងសម្រេច ។

**មាត្រា ១៤០.-**

នៅពេលគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតទទួលកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះ-ឆ្នោត ត្រូវចុះហត្ថលេខាលើទម្រង់បែបបទប្រគល់ ទទួល រួចប្រគល់ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមួយច្បាប់ និងទុកជាឯកសារមួយច្បាប់ ។

**មាត្រា ១៤១.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងបទបញ្ជា និងនីតិវិធី ដើម្បីអនុវត្តជាបន្ថែមទៀតសម្រាប់ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការរាប់សន្លឹកឆ្នោត ឲ្យបានត្រឹមត្រូវស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១៤២.-**

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗនោះ ។

ក្នុងការត្រួតពិនិត្យនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់ឃុំ សង្កាត់ នីមួយៗ គណៈ-កម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតមិនអាចបើកកញ្ចប់សន្លឹកឆ្នោតនៃឃុំ សង្កាត់ណាមួយ ឬ

ការិយាល័យបោះឆ្នោតណាមួយបានឡើយ ប្រសិនបើឃុំ សង្កាត់នោះ ឬការិយាល័យបោះឆ្នោតនោះ គ្មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់អំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ។

ចំពោះឃុំ សង្កាត់ណា ឬការិយាល័យបោះឆ្នោតណាដែលមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតអាចបើក និងពិនិត្យមើលសម្ភារបោះឆ្នោត និងអាចរាប់សន្លឹកឆ្នោតឡើងវិញ ប្រសិនបើចាំបាច់ ។

ក្នុងករណីឃុំ សង្កាត់ណាដែលមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលមានលក្ខណៈសមស្របតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៤៩ នៃច្បាប់នេះ គណៈកម្មការរាជធានី ខេត្តរៀបចំ-ការបោះឆ្នោត ត្រូវបើកពិនិត្យមើលសម្ភារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតសាមី ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍នៃឃុំ សង្កាត់នោះ និងអ្នកជំទាស់ដូចមានចែងក្នុងមាត្រា ១៤៩ នៃច្បាប់នេះ អាចចូលរួមក្នុងដំណើរការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដោយគណៈកម្មការ-រាជធានី ខេត្តរៀបចំការបោះឆ្នោត ។

បន្ទាប់ពីបានត្រួតពិនិត្យនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់ឃុំ សង្កាត់ នីមួយៗចប់សព្វគ្រប់ហើយ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវធ្វើការកំណត់ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល និងត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ និងកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោតដែលទទួលតំណែងជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ចៅសង្កាត់ជំទប់ ចៅសង្កាត់រង ស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៣២ មាត្រា ៣៣ មាត្រា ៣៤ និងមាត្រា ៣៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ រួចហើយធ្វើសេចក្តីរាយការណ៍ភ្លាមទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមទម្រង់បែបបទដែលបានកំណត់។

ក្នុងការកំណត់បេក្ខជនជាប់ឆ្នោតទទួលតំណែងជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង ករណីបើមានបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើនមានសំឡេងឆ្នោតស្មើគ្នា គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវរៀបចំការចាប់ឆ្នោតទៅតាមនីតិវិធី ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

# ជំពូកទី ១១
# លទ្ធផលបណ្ដោះអាសន្ន លទ្ធផលផ្លូវការ
# និងការជំទាស់ចំពោះលទ្ធផលនៃការបោះឆ្នោត

**មាត្រា ១៤៣.-**

ក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ករណីពិនិត្យឃើញភាព មិនប្រក្រតី ដែលមិនអាចនាំទៅដល់ការផ្លាស់ប្ដូរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតទេ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវបំពេញបែបបទយល់ព្រម និងចុះហត្ថលេខា ហើយដាក់បង្ហាញការយល់ព្រមរបស់ខ្លួនចំពោះលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

**មាត្រា ១៤៤.-**

ក្នុងករណីមានភាពមិនប្រក្រតី ដែលនាំឲ្យមានការផ្លាស់ប្ដូរដល់លទ្ធផលបណ្ដោះអាសន្ននៃការបោះ-ឆ្នោត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវព្យួរលទ្ធផល បណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនោះ រួចហើយត្រូវបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ឬនៅការិយាល័យបោះឆ្នោតនោះ ដោយ ៖

-ប្រកាសថាលទ្ធផលនៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ឬនៅការិយាល័យនោះ ត្រូវបានបដិសេធ

-បំពេញទម្រង់បែបបទជូនដំណឹងស្ដីពីសេចក្ដីសម្រេចលើបណ្ដឹង ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោត ចុះហត្ថលេខា និងកាលបរិច្ឆេទ

-ប្រកាសថាសេចក្ដីសម្រេចរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ស្ថិតក្រោមការត្រួតពិនិត្យឡើងវិញនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ផ្ញើទម្រង់បែបបទជូនដំណឹងស្ដីពីសេចក្ដីសម្រេចលើបណ្ដឹងនោះ ជូនគណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោតមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្ដឹងជំទាស់មួយច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជននៅក្នុងឃុំ សង្កាត់ពាក់ព័ន្ធនោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**មាត្រា ១៤៥.-**

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវបញ្ជូនលិខិតជូនដំណឹងស្ដីពីសេចក្ដីសម្រេចនៃការបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះ

ឆ្នោតណាមួយមិនឲ្យលើសពី ២៤ (ម្ភៃបួន) ម៉ោងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីត្រួតពិនិត្យឡើងវិញ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យឡើងវិញ និងសម្រេចលើសេចក្តីសម្រេចនៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការ-បោះឆ្នោតមិនឲ្យលើសពី ០៤ (បួន) ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទ ជូនដំណឹងស្តីពីសេចក្តីសម្រេចលើពាក្យបណ្តឹង ។

**មាត្រា ១៤៦.-**

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនយល់ព្រមលើសេចក្តីសម្រេច នៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

-ប្រកាសថាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់នោះត្រូវចាត់ទុកថាត្រឹមត្រូវ

-បំពេញទម្រង់បែបបទតាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការមិនយល់ព្រម ចំពោះសេចក្តីសម្រេចរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

-ផ្ញើទម្រង់បែបបទនោះជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្តឹងមួយច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជននៅក្នុងឃុំ សង្កាត់នោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**មាត្រា ១៤៧.-**

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទទួលយល់ព្រមលើសេចក្តីសម្រេចនៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការ-បោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

-ប្រកាសថាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់នោះត្រូវបានបដិសេធ

-បំពេញទម្រង់បែបបទតាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

-ផ្ញើទម្រង់បែបបទនោះជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្តឹងមួយច្បាប់ ជូនគ្រប់

តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជននៅក្នុងឃុំ សង្កាត់នោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**មាត្រា ១៤៨.-**

ក្នុងករណីដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយ គណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោត ត្រូវចាត់ឲ្យធ្វើការបោះឆ្នោតសាជាថ្មីមិនលើសពី ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ។

ការបោះឆ្នោតសាជាថ្មីត្រូវធ្វើឡើងនៅក្នុងការិយាល័យបោះឆ្នោតដដែល ដោយយកបញ្ជីឈ្មោះអ្នកបោះឆ្នោតដដែល ព្រមទាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយដដែល ដូចគ្នានឹងការបោះឆ្នោតលើកមុន ។

បទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ៧ ជំពូកទី ៨ ជំពូកទី ៩ ជំពូកទី ១០ និងជំពូកទី ១១ នៃច្បាប់នេះ ត្រូវបានអនុវត្តចំពោះការបោះឆ្នោតសាជាថ្មីនេះ លើកលែងតែសន្លឹកឆ្នោតដែលត្រូវបោះពុម្ពលើក្រដាសពណ៌ផ្សេងពីលើកមុន ។

**មាត្រា ១៤៩ .-**

ជនគ្រប់រូប ដែលបានចុះឈ្មោះបោះឆ្នោតនៅលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ មានសិទ្ធិប្ដឹងជំទាស់ទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតអំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់នោះ ។

ការប្ដឹងជំទាស់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ។

ការប្ដឹងជំទាស់ ត្រូវផ្អែកលើភាពមិនប្រក្រតីក្នុងដំណើរការនៃការបោះឆ្នោតដែលនាំឲ្យផ្លាស់ប្ដូរដល់លទ្ធផលនៃការបោះឆ្នោត ។

ការប្ដឹងជំទាស់ត្រូវមានមូលដ្ឋានច្បាស់លាស់ ដោយបង្ហាញអំពីទីកន្លែង និងពេលវេលាដែលមានភាពមិនប្រក្រតី ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី និងសេចក្ដីអះអាងគាំទ្រ ឬភស្តុតាងផ្សេងទៀត ។

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវសម្រេចលើការប្ដឹងជំទាស់នេះ ក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យប្ដឹងជំទាស់ ។

ROYAUME DU CAMBODGE - MINISTÈRE DU PALAIS ROYAL

**មាត្រា ១៥០.–**

ក្នុងករណីគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតរកឃើញថា ការប្តឹងជំទាស់ពុំមានមូលដ្ឋានសមហេតុសមផល ឬពុំមានឥទ្ធិពលធ្វើឲ្យផ្លាស់ប្តូរដល់លទ្ធផលនៃការបោះឆ្នោតគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវបដិសេធ ការប្តឹងជំទាស់នោះ ដោយ ៖

–ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ថា ការប្តឹងជំទាស់នោះត្រូវបានបដិសេធ

–បំពេញទម្រង់បែបបទបដិសេធតាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

–ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ថា សាមីខ្លួន ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ទៅគណៈកម្មាធិការជាតិរៀបចំការ-បោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៤ (បួន) ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ

–ផ្តល់ទម្រង់បែបបទដល់អ្នកប្តឹងជំទាស់ ឬតំណាងសម្រាប់ប្តឹងតវ៉ា

–ផ្ញើទម្រង់បែបបទបដិសេធនោះ ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយច្បាប់ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្តឹងជំទាស់មួយច្បាប់ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនក្នុងឃុំ សង្កាត់នោះ មួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**មាត្រា ១៥១.–**

ក្នុងករណីគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតយល់ព្រមចំពោះការប្តឹងជំទាស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវបដិសេធលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះដោយ ៖

–ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ថា ការប្តឹងជំទាស់នោះត្រូវបានយល់ព្រម

–ប្រកាសថាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬក្នុងការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់នោះត្រូវបានបដិសេធ

–បំពេញទម្រង់បែបបទបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

–ប្រកាសថាសេចក្តីសម្រេចរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតស្ថិតក្រោមការត្រួតពិនិត្យឡើងវិញដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

–ផ្ញើទម្រង់បែបបទបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនោះ ជូនគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោតមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមួយច្បាប់ជូនអ្នកប្តឹងជំទាស់មួយច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជននៅក្នុងឃុំ សង្កាត់

នោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**មាត្រា ១៥២.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យឡើងវិញនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ឬក្នុងការិយាល័យបោះឆ្នោតណាមួយដែលមានការប្តឹងជំទាស់ក្នុងរយៈពេលយ៉ាងយូរ ០៤ (បួន) ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទ ប្តឹងតវ៉ាដូចមានចែងក្នុងមាត្រា ១៥០ នៃច្បាប់នេះ ឬទម្រង់បែបបទបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដូចមានចែងក្នុងមាត្រា ១៥១ នៃច្បាប់នេះ ។

ក្នុងការត្រួតពិនិត្យឡើងវិញនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ឬក្នុងការិយាល័យបោះឆ្នោតណាមួយដែលមានការប្តឹងជំទាស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចបើកពិនិត្យមើលសម្ភារបោះឆ្នោត និងអាចរាប់សន្លឹកឆ្នោតនៅឃុំ សង្កាត់នោះ ឬការិយាល័យបោះឆ្នោតនោះឡើងវិញប្រសិនបើចាំបាច់ ។

ក្នុងករណីឃុំ សង្កាត់ណាដែលមានសំឡេងឆ្នោតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដែលមានលក្ខណៈសមស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤៩ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការ-បោះឆ្នោត ត្រូវបើកពិនិត្យមើលសម្ភារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។

ដំណើរការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតខាងលើនេះ ត្រូវធ្វើចំពោះមុខភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹងជំទាស់ដែលមានការពាក់ព័ន្ធ ។

**មាត្រា ១៥៣.–**

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរកឃើញថា ការប្តឹងជំទាស់ទាក់ទងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយ ពុំមានមូលដ្ឋានសមហេតុសមផល ឬពុំមានឥទ្ធិពល ធ្វើឲ្យផ្លាស់ប្តូរដល់លទ្ធផលនៃការបោះឆ្នោតគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ត្រូវបដិសេធការប្តឹងជំទាស់នោះ ដោយ ៖

–ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ ឬតំណាងថា ការប្តឹងជំទាស់នោះត្រូវបានបដិសេធ

–ប្រកាសថាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬការិយាល័យនោះត្រូវចាត់ទុកថាត្រឹមត្រូវ

–បំពេញទម្រង់បែបបទបដិសេធការប្តឹងជំទាស់តាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

–ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ ឬតំណាងថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោត ជាសេចក្តីសម្រេចចុងក្រោយ

-ផ្ញើទម្រង់បែបបទបដិសេធនោះ ជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្ដឹងជំទាស់មួយច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនក្នុងឃុំ សង្កាត់នោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**មាត្រា ១៥៤.-**

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ព្រមចំពោះការប្ដឹងជំទាស់ទៅនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

-ផ្ដល់ដំណឹងដល់អ្នកប្ដឹងជំទាស់ ឬតំណាងថា ការប្ដឹងជំទាស់នោះត្រូវបានយល់ព្រម

-ប្រកាសថាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ឬក្នុងការិយាល័យបោះឆ្នោតនោះ ត្រូវបានបដិសេធ

-បំពេញទម្រង់បែបបទដែលបានកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធចំពោះលទ្ធផលនៃការបោះឆ្នោត រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

-ផ្ញើទម្រង់បែបបទនោះ ជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនក្នុងឃុំ សង្កាត់នោះមួយច្បាប់ ជូនអ្នកប្ដឹងជំទាស់មួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសេចក្ដីសម្រេចចុងក្រោយ ។

**មាត្រា ១៥៥.-**

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឲ្យអនុវត្តនូវបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ១៤៨ នៃច្បាប់នេះ ។

**មាត្រា ១៥៦.-**

បន្ទាប់ពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ ពិនិត្យឡើងវិញឃើញថាត្រឹមត្រូវ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រកាសជាសាធារណៈ នូវលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះភ្លាម ។

ចំពោះឃុំ សង្កាត់ណាដែលមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់អំពីលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោត ការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងឃុំ សង្កាត់នោះត្រូវធ្វើបន្ទាប់ពីការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់ ត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរទៅតាមនីតិវិធី ដូចមានចែងក្នុងច្បាប់នេះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្តល់នូវលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ជូននាយករដ្ឋមន្ត្រីមួយច្បាប់ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមួយច្បាប់ និងត្រូវបិទផ្សាយជាសាធារណៈនូវលទ្ធផលនេះនៅទីស្នាក់ការគណៈកម្មការ រាជធានី ខេត្តរៀបចំការបោះឆ្នោតសាមីមួយច្បាប់ នៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតសាមីមួយច្បាប់ និងទុកជាឯកសារមួយច្បាប់ ។

**មាត្រា ១៥៧.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំទុកដាក់ឲ្យមានសុវត្ថិភាពនូវ ឯកសារបោះឆ្នោតទាំងអស់ ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដូចខាងក្រោម ៖

–កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងឯកសារប្តឹងតវ៉ា និងប្តឹងជំទាស់ ព្រមទាំងសេចក្តីសម្រេចដោះស្រាយរបស់អាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំទុកដាក់ឲ្យមានសុវត្ថិភាពជារៀងរហូត

–សន្លឹកឆ្នោតទាំងអស់ ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តាមអាណត្តិនីមួយៗ ត្រូវរៀបចំទុកដាក់ឲ្យមានសុវត្ថិភាពក្នុងរយៈពេល ០៣ (បី) ឆ្នាំ បន្ទាប់ពីថ្ងៃបោះឆ្នោត ។ បន្ទាប់ពីរយៈពេលនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបង្កើតគណៈកម្មការមួយ ដើម្បីបំផ្លាញចោលនូវសន្លឹកឆ្នោតទាំងនោះ ។

**មាត្រា ១៥៨.–**

បេក្ខជនដែលបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមច្បាប់នេះនឹងក្លាយទៅជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់អាណត្តិ ០៥ (ប្រាំ) ឆ្នាំ ចាប់តាំងពីពេលចូលកាន់តំណែង ហើយនឹងត្រូវបញ្ចប់អាណត្តិរបស់ខ្លួន ដោយផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ១៥៩.–**

ក្នុងអំឡុងពេលបោះឆ្នោត ពេលរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀង ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៧៤ នៃច្បាប់នេះ ។

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវរារាំងដល់ការប្រើប្រាស់សេរីភាព ក្នុងការបញ្ចេញមតិដែលស្របតាមច្បាប់ជាធរមាន ។

## ជំពូកទី ១២
## ការបិទការិយាល័យបោះឆ្នោតក្នុងគ្រាមានអាសន្ន

### មាត្រា ១៦០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិសម្រេចមិនបើកការិយាល័យ បោះឆ្នោត និងមានសិទ្ធិបិទការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួន ក្នុងកាលៈទេសៈមានអាសន្នដែលនាំឲ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងបរិវេណខាងក្នុង ។

កាលៈទេសៈមានអាសន្នអាចមានករណីណាមួយ ក្នុងចំណោមករណីដូចខាងក្រោម ៖

-អសន្តិសុខជាសាធារណៈ

-ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី ឬគ្រោះធម្មជាតិផ្សេងទៀត

-ការដួលរលំអគារសម្រាប់បម្រើការបោះឆ្នោត ដោយយថាហេតុណាមួយ អគ្គិភ័យ ឬការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឲ្យមានគ្រោះថ្នាក់

-ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឲ្យការបោះឆ្នោតដំណើរការបាន។

ការិយាល័យបោះឆ្នោតដែលមិនបានបើក ឬដែលបានបិទតាមមាត្រានេះ ត្រូវតែបិទរហូតពេញមួយថ្ងៃ ។

### មាត្រា ១៦១.-

ក្នុងករណីការិយាល័យបោះឆ្នោតណាមួយ ត្រូវបិទគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរាយការណ៍ភ្លាមជូននាយករដ្ឋមន្ត្រី ។

### មាត្រា ១៦២.-

ក្នុងករណីការិយាល័យបោះឆ្នោតណាមួយត្រូវបិទ ការបោះឆ្នោតនៅការិយាល័យនោះ ត្រូវធ្វើសាជាថ្មីក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃក្រោយនៅទីកន្លែងសមស្រប ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

អ្នកបោះឆ្នោតទាំងអស់ដែលមានសិទ្ធិបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ត្រូវអនុញ្ញាតឲ្យបោះឆ្នោត ទោះបីជាអ្នកទាំងនោះបានបោះឆ្នោតហើយក្តី ឬមិនទាន់បានបោះឆ្នោតក្តី ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឲ្យមានសន្លឹកឆ្នោតគ្រប់ចំនួន ដែលបោះពុម្ពលើក្រដាសពណ៌ផ្សេងពីលើកមុន ។

**មាត្រា ១៦៣.–**

សន្លឹកឆ្នោតដែលបានបោះនៅក្នុងការិយាល័យបោះឆ្នោត ដែលបានបិទស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៦០ នៃច្បាប់នេះ មិនត្រូវយកមករាប់ឡើយ មានតែសន្លឹកឆ្នោត ដែលបានបោះនៅថ្ងៃបោះឆ្នោតដែលត្រូវធ្វើសាជាថ្មីប៉ុណ្ណោះដែលត្រូវយកមករាប់ ។

ចំពោះសន្លឹកឆ្នោតដែលមិនត្រូវយកមករាប់ មន្ត្រីការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុ និងរៀបចំទុកដាក់ស្របតាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ។

សន្លឹកឆ្នោតដែលបានបោះនៅគ្រប់ការិយាល័យបោះឆ្នោត ដែលមិនបានបិទ ត្រូវយកមករាប់ និងកត់ត្រានៅថ្ងៃបោះឆ្នោត ។

សន្លឹកឆ្នោតទាំងអស់ត្រូវរាប់ និងកត់ត្រាតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

បន្ទាប់ពីការបោះឆ្នោតសាជាថ្មី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឲ្យបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងមូល និងប្រកាសលទ្ធផលស្របតាមនីតិវិធី ដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ១៦៤.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងនូវបទបញ្ជា និងនីតិវិធីសម្រាប់ការអនុវត្តជាក់ស្តែងបន្ថែមទៀតនូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៦០ មាត្រា ១៦២ និងមាត្រា ១៦៣ នៃច្បាប់នេះ ដែលរួមមាន ៖

–សុវត្ថិភាពនៃមន្ត្រីបោះឆ្នោត អ្នកបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

–តួនាទីរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

–ការប្រគល់ ការថែរក្សា ការទទួល និងសុវត្ថិភាពនៃសម្ភារបោះឆ្នោតទាំងអស់

–ការបិទការិយាល័យបោះឆ្នោត និងការបើកការិយាល័យបោះឆ្នោតឡើងវិញ

–ដំណើរការបោះឆ្នោតសាជាថ្មី

–ការរាប់សន្លឹកឆ្នោត

–ការប្រកាសលទ្ធផលនៃការបោះឆ្នោត ។

# ជំពូកទី ១៣
# ការបោះឆ្នោតឡើងវិញ

**មាត្រា ១៦៥.-**

ការបោះឆ្នោតឡើងវិញដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ត្រូវធ្វើឡើងក្នុងរយៈពេលមិនឲ្យលើសពី ១២០ (មួយរយម្ភៃ) ថ្ងៃឡើយ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការបោះឆ្នោតឡើងវិញក្នុង រយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីមានករណីដែលតម្រូវឲ្យមានការបោះឆ្នោតឡើងវិញ ។

ការបោះឆ្នោតត្រូវចាប់ធ្វើពីម៉ោង ៧:០០ នាទី ដល់ម៉ោង ១៥:០០ នាទី ក្នុងថ្ងៃដដែល ។

**មាត្រា ១៦៦.-**

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតសម្រាប់ការបោះឆ្នោតឡើងវិញ លុះត្រាតែមានឈ្មោះក្នុង បញ្ជីឈ្មោះអ្នកបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

បញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវយកបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ ។

អ្នកបោះឆ្នោតដែលបានចុះឈ្មោះម្នាក់ៗ មានសិទ្ធិបោះឆ្នោតតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈ សន្លឹកឆ្នោតសម្ងាត់ ។

**មាត្រា ១៦៧.-**

ការបោះឆ្នោតឡើងវិញត្រូវប្រព្រឹត្តទៅក្រោមការគ្រប់គ្រង និងចាត់ចែងដោយគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត អនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១៦៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលខុសត្រូវចំពោះការបោះឆ្នោតឡើងវិញ ។

បទប្បញ្ញត្តិសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដូចមានចែងក្នុងច្បាប់នេះ ត្រូវអនុវត្តចំពោះការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិតាក់តែងបទបញ្ជា និងនីតិវិធី ដើម្បីធានា ឲ្យការបោះឆ្នោតឡើងវិញប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

# ជំពូកទី ១៤
# ទោសប្បញ្ញត្តិ

## មាត្រា ១៦៩.–

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម ៖

–ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះ-ឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

–ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាចបោះឆ្នោតបាន ។

## មាត្រា ១៧០.–

ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណពាក់ព័ន្ធនឹងការបោះឆ្នោត ។

## មាត្រា១៧១ .. ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

-រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

-បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។

-ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោត ប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។

-រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

-ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

-រាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។

-ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

-ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

-បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

-បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។

-ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

-ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្ម ដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៧២ .- ថ្មី**

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើនេះ។

បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ គណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើ អាចត្រូវបានដកសិទ្ធិមិនឱ្យចូលរួមការបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ១៧៣.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដោយទុច្ចរិតព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ លើកលែងតែមានការអនុញ្ញាតដោយច្បាប់នេះ ។

**មាត្រា ១៧៤.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំដោយគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិច ដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

**មាត្រា ១៧៥.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ

គ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ដោយបំពានលើបញ្ញត្តិនៃមាត្រា ២៨ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឲ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៧៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឲ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឲ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្ដេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១០ នៃច្បាប់នេះ ។

**មាត្រា ១៧៧.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណា ដែលនៅក្នុងពេលបោះឆ្នោត បង្ខាប់បញ្ជាលួងលោម បោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឲ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឲ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុង កថាខណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៧៨.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណា ដោយចេតនាធ្វើឲ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឲ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឲ្យបាត់ ដកហូត លួច ដណ្ដើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឲ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែង ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៧៩.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលបំពានលើបញ្ញត្តិ នៃមាត្រា ៧៤ នៃច្បាប់នេះ ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះ អំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ ។

**មាត្រា ១៨០.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាតាមបែបបទ ដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍ ។

**មាត្រា ១៨១.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឲ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាក់លាក់នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណី ដែលជនប្រព្រឹត្តអំពើល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

**មាត្រា ១៨២.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀប-ចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១៨១ ខាងលើនេះ ។

**មាត្រា ១៨៣.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃមាត្រា ៧៨ នៃច្បាប់នេះ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៨៤.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី ១ នៃមាត្រា ៧០ នៃច្បាប់នេះ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

**មាត្រា ១៨៥.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១៨៤ ខាងលើនេះ ។

**មាត្រា ១៨៦.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាឲ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៨៧.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៥៩ នៃច្បាប់នេះ ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ ។

**មាត្រា ១៨៨.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត ។

ROYAUME DU CAMBODGE - LE MINISTERE DU PALAIS ROYAL

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៨៩.-**

តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរមានសមត្ថកិច្ច អាចសម្រេចដាក់ទណ្ឌកម្មវិន័យ ដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ចំពោះអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងពេលបំពេញមុខងារ ដែលបានបំពានបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១៩០.-**

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ ។

អង្គការ ឬអ្នកតំណាងរបស់គណបក្សនយោបាយ សំដៅដល់អង្គការ ឬបុគ្គល ដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ ។

**មាត្រា ១៩១.-**

សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានចែងនៅក្នុងជំពូកនេះ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

បែបបទ និងនីតិវិធី ដើម្បីចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៩២.-**

ដំណើរការនីតិវិធី ដើម្បីចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនរារាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិ ដែលចែងនៅក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ ។

**មាត្រា ១៩៣ .-**

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី ១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី ៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្តីសម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ ។

## ជំពូកទី ១៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៩៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីបោះឆ្នោតថ្មី សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៤ ស្របតាមបទប្បញ្ញត្តិនៃមាត្រា ១៦៧ មាត្រា ១៦៨ និងមាត្រា ១៦៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

## ជំពូកទី ១៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៩៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា ១៩៦.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៥

នស/រកម/១២១៥/០២៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ១១៣៤ ស.ណ
សំណៅចម្លងមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
**សយ សុខា**

**មាត្រាពីរ..**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣ស.១៧/១០.៩៤៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៧៨៤ ស.ណ

**សំណៅដែលមានចំលងត្រឹមត្រូវជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

## មាត្រាប្រាំមួយ .- វិសោធនកម្មដោយការកែប្រែមាត្រាពាក់ព័ន្ធមួយចំនួននៅក្នុងច្បាប់បោះឆ្នោត

...

"មាត្រា៣៥" នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានចែងក្នុងមាត្រា៤៥ មាត្រា៤៦ និងមាត្រា៥៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានកែប្រែទៅជា "មាត្រា៣៥ថ្មី" ដែលមានខ្លឹមសារដូចមានចែងក្នុងមាត្រាបីនៃច្បាប់នេះ។ "មាត្រា៤៥" "មាត្រា៤៦" "មាត្រា៤៨" និង "មាត្រា៥៩" ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានកែប្រែតាមលំដាប់លំដោយទៅជា "មាត្រា៤៥ថ្មី" "មាត្រា៤៦ថ្មី" "មាត្រា៤៨ថ្មី" និង "មាត្រា៥៩ថ្មី"។

...

...

## មាត្រាប្រាំពីរ .- អវសានប្បញ្ញត្តិ

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ អង្គារ ២រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០២៣

នរោត្តម សីហមុនី

នស.រកម.០៧២៣.០១៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បោះពុម្ពផ្សាយដោយ

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

( គ.ជ.ប )

ឆ្នាំ២០២៦

ស្កេនដើម្បីទទួលបាន
សៀវភៅជា PDF


មហាវិថីសម្ដេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ, កម្ពុជា
Samdach Sothearos Blvd, Sangkat Tonle Bassac, Khan Chamkar Morn, Phnom Penh, Cambodia

ទូរសព្ទ : (+855) 23 23 52 53
អ៊ីម៉ែល : info@nec.gov.kh